ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២៦ លេខ៤១ ត្រីមាសទី០២ ឆ្នាំ២០២៦

# រាជកិច្ច

ផ្សាយចេញពី

## ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស សារាចរ ប្រកាស

# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


| | | |
|---|---|---|
| ៣០-៥-២០២៦ | -ព្រះរាជក្រម នស/រកម/០៥២៦/០០៩ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនអគ្គិសនីវៀតណាមនៃសាធារណរដ្ឋសង្គមនិយមវៀតណាមសម្រាប់ការធានាលើការទិញថាមពលអគ្គិសនីពីប្រទេសវៀតណាម | ៤៨៩៩ |


### ២~ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ២៨-៥-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៥២៦/៥៨៣ ស្តីពី ការតែងតាំងមុខតំណែង នៅក្រសួងអធិការកិច្ច ដល់មន្ត្រីរាជការ ៣រូប | ៤៩២១ |
| ២៨-៥-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៥២៦/៥៨៤ ស្តីពី ការដាក់ឱ្យចូលនិវត្តន៍មុនអាយុកំណត់ដល់មន្ត្រីរាជការ ៣រូប នៅក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ តាមការស្នើសុំរបស់សាមីខ្លួន | ៤៩២៣ |
| ២៨-៥-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៥២៦/៥៨៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌតាមលំដាប់ថ្នាក់ ប្រគេនព្រះសង្ឃ និងជូនថ្នាក់ដឹកនាំអង្គការ សប្បុរសជន ៨អង្គ/រូប | ៤៩២៥ |
| ២៨-៥-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៥២៦/៥៨៦ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី នាយទាហាន នៃកងយោធពលខេមរភូមិន្ទជាកិច្ចបច្ឆាមរណៈ ដល់យោធិនដែលបានពលីជីវិតក្នុងបុព្វហេតុការពារបូរណភាពទឹកដី នៃការរំលោភឈ្លានពានពីបច្ចាមិត្ត ចំនួន ២រូប | ៤៩២៦ |
| ២៨-៥-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៥២៦/៥៨៧ ស្តីពី ការអនុញ្ញាតឱ្យឧត្តមសេនីយ៍ត្រី **អៀង ហ៊ារត** លាឈប់ពីក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ | ៤៩២៧ |
| ៣០-៥-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៥២៦/៥៩២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌតាមលំដាប់ថ្នាក់ ដល់ថ្នាក់ដឹកនាំអង្គការដៃគូអភិវឌ្ឍ និងមន្ត្រីរាជការ នៃក្រសួងអប់រំ យុវជន និងកីឡា ៨រូប | ៤៩២៨ |
| ៣០-៥-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៥២៦/៥៩៣ ស្តីពី លក្ខន្តិកៈនៃអង្គគ្រូបង្រៀន | ៤៩២៩ |
| ២-៦-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៦២៦/៥៩៥ ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌដល់លោក **ឈួរ ពន្លឺ** នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្តីការគណៈរដ្ឋមន្ត្រី | ៤៩៤៧ |
| ២-៦-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៦២៦/៥៩៦ ស្តីពី ការបន្ថយឋានន្តរស័ក្តិ ពី ឧត្តមសេនីយ៍ទោ ឱ្យមកនៅត្រឹមថ្នាក់ ឧត្តមសេនីយ៍ត្រី នាយនគរបាល ថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ២រូប | ៤៩៤៨ |
| ២-៦-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៦២៦/៥៩៧ ស្តីពី ការដាក់ឱ្យចូលនិវត្តន៍មុនអាយុកំណត់ដល់លោក **ម៉ិន ឫទ្ធី** នៅក្រសួងមុខងារសាធារណៈ តាមការស្នើសុំរបស់សាមីខ្លួន និងដាក់ឱ្យចូលនិវត្តន៍ដល់មន្ត្រីរាជការ ១៨២ រូប នៅក្រសួង ស្ថាប័នចំនួន ២៩ | ៤៩៤៩ |

# ខ

## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


| | | |
|---|---|---|
| ៤-៥-២០២៦ | -អនុក្រឹត្យលេខ ៧៧ អនក្រ.បក ស្ដីពី ការទទួលស្គាល់វិទ្យាស្ថាន ថាក់ គ្លូប៊ល | ៤៩៥៩ |
| ៦-៥-២០២៦ | -អនុក្រឹត្យលេខ ៧៨ អនក្រ.បក ស្ដីពី ការផ្ទេរទ្រព្យសម្បត្តិរដ្ឋ និងការកែសម្រួលទំហំដី | ៤៩៦២ |
| ៦-៥-២០២៦ | -អនុក្រឹត្យលេខ ៧៩ អនក្រ.បក ស្ដីពី ការផ្ទេរទ្រព្យសម្បត្តិរដ្ឋ | ៤៩៨៧ |
| ៤-៥-២០២៦ | -អនុក្រឹត្យលេខ ៤០២ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ | ៤៩៨៩ |
| ៤-៥-២០២៦ | -អនុក្រឹត្យលេខ ៤០៣ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ | ៤៩៩១ |
| ៤-៥-២០២៦ | -អនុក្រឹត្យលេខ ៤០៤ អនក្រ.តត ស្ដីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ | ៤៩៩៣ |
| ៤-៥-២០២៦ | -អនុក្រឹត្យលេខ ៤០៥ អនក្រ.តត ស្ដីពី ការតែងតាំងជំនួយការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ៤៩៩៥ |


### ២~សេចក្ដីសម្រេច


| | | |
|---|---|---|
| ៦-៥-២០២៦ | -សេចក្ដីសម្រេចលេខ ៥៥ សសរ ស្ដីពី ការបង្កើតក្រុមការងារចំពោះកិច្ចទទួលបន្ទុកពិនិត្យ និងវាយតម្លៃលើលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសវិនិយោគិនក្នុងវិស័យឧស្សាហកម្មកែច្នៃស្វាយចន្ទីនៅក្នុង និងក្រៅតំបន់សេដ្ឋកិច្ចពិសេស | ៤៩៩៧ |


## III~ការងារបណ្ដាក្រសួង

### ១~ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


| | | |
|---|---|---|
| ៤-៥-២០២៦ | -ប្រកាសអន្តរក្រសួងលេខ ៣៤៩ សហវ.ប្រក.អរតន ស្ដីពី ការបង្កើតរដ្ឋទេយ្យចំណូលនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ៥០០២ |
| ១៣-៥-២០២៦ | -ប្រកាសអន្តរក្រសួងលេខ ៣៦៩ សហវ.ប្រក.អទច ស្ដីពី ការផ្ដល់សេវាសាធារណៈរហ័សលើវិស័យសុរិយោដី និងភូមិសាស្ត្ររបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ៥០០៥ |


### ២~ទីស្ដីការរដ្ឋមន្ត្រីក្រសួងផែនការ


| | | |
|---|---|---|
| ៣-៤-២០២៦ | -ប្រកាសអន្តរក្រសួងលេខ ២៥៦ ផក ស្ដីពី ការផ្លាស់ប្ដូរទិន្នន័យសុខាភិបាល | ៥០០៨ |

# ព្រះរាជក្រម

នស/រកម/០៥២៦/០០៩

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សម្ពហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុនអគ្គិសនីវៀតណាមនៃសាធារណរដ្ឋសង្គមនិយមវៀតណាមសម្រាប់ការធានាលើការទិញថាមពលអគ្គិសនីពីប្រទេសវៀតណាម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៦ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៦ នាសម័យប្រជុំព្រឹទ្ធសភាលើកទី៥ នីតិកាលទី៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

# ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុនអគ្គិសនីវៀតណាម នៃសាធារណរដ្ឋសង្គមនិយមវៀតណាមសម្រាប់ការធានា លើការទិញថាមពលអគ្គិសនីពីប្រទេសវៀតណាម



**មាត្រា១ .–**

អនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចំពោះអគ្គិសនីកម្ពុជា ឱ្យក្រុមហ៊ុនអគ្គិសនីវៀតណាមនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងទិញ-លក់ថាមពលអគ្គិសនី រវាងអគ្គិសនីកម្ពុជានិងក្រុមហ៊ុនអគ្គិសនីវៀតណាម ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៦។ ការធានានេះមានអត្ថបទទាំងស្រុងដែលបានចុះហត្ថលេខាកាលពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៦ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃរាជរដ្ឋាភិបាលកម្ពុជា ភ្ជាប់មកជាមួយនេះ។

**មាត្រា២ .–**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តពល់នីតិវិធីដើម្បីអនុវត្តលិខិតធានាទូទាត់នេះ។

**មាត្រា៣ .–**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ *សៅរ៍ ១៤ កើត* ខែ *ចេត្រ* ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី *៣០* ខែ *មេសា* ឆ្នាំ២០២៦

**ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

*ពរស. ២៦០៥. ៥៩៦*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# សេចក្តីព្រាង

# ច្បាប់

# ស្តីពី

# ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុនអគ្គិសនីវៀតណាម នៃសាធារណរដ្ឋសង្គមនិយមវៀតណាមសម្រាប់ការធានា លើការទិញថាមពលអគ្គិសនីពីប្រទេសវៀតណាម

**មាត្រា១ .-**

អនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចំពោះអគ្គិសនីកម្ពុជា ឱ្យក្រុមហ៊ុនអគ្គិសនីវៀតណាមនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងទិញ-លក់ថាមពលអគ្គិសនី រវាងអគ្គិសនីកម្ពុជានិងក្រុមហ៊ុនអគ្គិសនីវៀតណាម ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៦។ ការធានានេះមានអត្ថបទទាំងស្រុងដែលបានចុះហត្ថលេខាកាលពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៦ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃរាជរដ្ឋាភិបាលកម្ពុជា ភ្ជាប់មកជាមួយនេះ។

**មាត្រា២ .-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តលិខិតធានាទូទាត់នេះ។

**មាត្រា៣ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ខែ ឆ្នាំ២០២៦
នាសម័យប្រជុំរដ្ឋសភាលើកទី នីតិកាលទី៧។

ថ្ងៃ ខែ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៦

**ប្រធានរដ្ឋសភា**

**សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី**



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០៨...ក/ផ្ដណ...កបម

# សេចក្ដីថ្លែងហេតុ
## អំពី
## សេចក្ដីព្រាងច្បាប់ស្ដីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុនអគ្គិសនីវៀតណាមនៃសាធារណរដ្ឋសង្គមនិយមវៀតណាមសម្រាប់ការធានាលើការទិញថាមពលអគ្គិសនីពីប្រទេសវៀតណាម

រាជរដ្ឋាភិបាលដែលមានក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការ បានយកចិត្តទុកដាក់ជំរុញការអភិវឌ្ឍវិស័យថាមពល ទាំងប្រភពថាមពលនិងបណ្ដាញបញ្ជូនអគ្គិសនី ដើម្បីធានានិរន្តរភាព ស្ថិរភាព ប្រសិទ្ធភាព តម្លៃសមរម្យ និងឆ្លើយតបទៅនឹងកំណើនតម្រូវការអគ្គិសនី។ ប្រភពថាមពលដែលកម្ពុជាបានអភិវឌ្ឍកន្លងមក រួមមាន ស្ថានីយវារីអគ្គិសនី ស្ថានីយវារីអគ្គិសនីបូមទឹកស្តុកទុក ស្ថានីយផលិតអគ្គិសនីដុតធ្យូងថ្ម ស្ថានីយផលិតអគ្គិសនីដុតឧស្ម័នធម្មជាតិ ស្ថានីយផលិតអគ្គិសនីដើរដោយខ្យល់ និងស្ថានីយផលិតអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ។ ទន្ទឹមនឹងការអភិវឌ្ឍប្រភពអគ្គិសនីក្នុងស្រុកបន្ថែមជាបន្តបន្ទាប់ ព្រះរាជាណាចក្រកម្ពុជាក៏ចាំបាច់ត្រូវការនាំចូលប្រភពអគ្គិសនីបន្ថែមពីប្រទេសជិតខាងផងដែរ ដើម្បីធានាឱ្យបាននូវសន្តិសុខថាមពលជាតិ។

អគ្គិសនីកម្ពុជានិងអគ្គិសនីវៀតណាមបានចុះកិច្ចព្រមព្រៀងទិញ-លក់អគ្គិសនី តាមរយៈខ្សែបញ្ជូនតង់ស្យុងខ្ពស់២៣០គីឡូវ៉ុល ចូវដុក-តាកែវ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០០ ហើយបានចាប់ផ្ដើមអនុវត្តការទទួលយកថាមពលនៅចុងខែមីនា ឆ្នាំ២០០៩ សម្រាប់ខេត្តតាកែវ និងចុងខែឧសភា ឆ្នាំ២០០៩ មកដល់រាជធានីភ្នំពេញ ដែលមានអានុភាព៨០មេហ្គាវ៉ាត់។ ចាប់ពីខែសីហា ឆ្នាំ២០១៤ អគ្គិសនីវៀតណាម បានដំឡើងអានុភាពដល់២០០មេហ្គាវ៉ាត់ និងបានបង្កើនអានុភាពផ្គត់ផ្គង់រហូតដល់២៥០មេហ្គាវ៉ាត់ ចាប់ពីពាក់កណ្ដាលខែមេសា ឆ្នាំ២០១៩។ អាណត្តិនៃកិច្ចព្រមព្រៀងដំបូងមានរយៈពេល១០ឆ្នាំ ត្រូវបានបញ្ចប់កាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩។ ប៉ុន្តែដោយកិច្ចសហប្រតិបត្តិការល្អ ភាគីទាំងពីរបានបន្តអាណត្តិនៃកិច្ចព្រមព្រៀងរហូតដល់មានការចុះកិច្ចព្រមព្រៀងទិញ-លក់អគ្គិសនីជាថ្មី នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០។ ភាគីទាំងពីរបានអនុវត្តកិច្ចព្រមព្រៀងរយៈពេល៥ឆ្នាំ និងបានពន្យារបន្តរយៈពេល១ឆ្នាំ ដែលត្រូវបានបញ្ចប់អាណត្តិ នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០២៦ កន្លងមកនេះ។ ភាគីទាំងពីរបានឯកភាពគ្នាចុះហត្ថលេខាលើកិច្ចព្រមព្រៀងថ្មី នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៦ ដែលមានសុពលភាពគិតចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២៦ រហូតដល់ថ្ងៃទី១ ខែមេសា ឆ្នាំ២០៣០ ដើម្បីជំនួសកិច្ចព្រមព្រៀងចាស់។ កិច្ចព្រមព្រៀងថ្មីនេះ កំណត់ថ្លៃទិញ-លក់ថាមពលអគ្គិសនី ដូចខាងក្រោម៖

១- រដូវប្រាំង(ពីថ្ងៃទី១ ខែវិច្ឆិកា ដល់ថ្ងៃទី៣០ ខែមិថុនា) ចែកចេញជា៣តម្លៃ៖

- ម៉ោងតម្រូវការខ្ពស់ តម្លៃ០,១៥២១ដុល្លារអាម៉េរិក/គីឡូវ៉ាត់ម៉ោង
- ម៉ោងតម្រូវការធម្មតា តម្លៃ០,១៣៥២ដុល្លារអាម៉េរិក/គីឡូវ៉ាត់ម៉ោង
- ម៉ោងតម្រូវការទាប តម្លៃ០,១១៤៩ដុល្លារអាម៉េរិក/គីឡូវ៉ាត់ម៉ោង។

២- រដូវវស្សា(ពីថ្ងៃទី១ ខែកក្កដា ដល់ថ្ងៃទី៣១ ខែតុលា) ចែកចេញជា៣តម្លៃ៖

- ម៉ោងតម្រូវការខ្ពស់ តម្លៃ០,១៤៣៦ដុល្លារអាម៉េរិក/គីឡូវ៉ាត់ម៉ោង
- ម៉ោងតម្រូវការធម្មតា តម្លៃ០,១១៨៣ដុល្លារអាម៉េរិក/គីឡូវ៉ាត់ម៉ោង
- ម៉ោងតម្រូវការទាប តម្លៃ០,១០១៤ដុល្លារអាម៉េរិក/គីឡូវ៉ាត់ម៉ោង។

តាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងថ្មីនេះ ក៏ដូចជាកិច្ចព្រមព្រៀងមុនៗដែរ ភាគីកម្ពុជាមានកាតព្វកិច្ចផ្តល់លិខិតធានាជូនភាគីអគ្គិសនីវៀតណាម ក្នុងរយៈពេលយ៉ាងយូរ៦ខែ គិតចាប់ពីថ្ងៃចុះកិច្ចព្រមព្រៀង ដែលត្រូវនឹងថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៦ ដើម្បីជំនួសលិខិតធានាចាស់ដែលបានផុតសុពលភាព។

សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុនអគ្គិសនីវៀតណាមនៃសាធារណរដ្ឋសង្គមនិយមវៀតណាមសម្រាប់ការធានាលើការទិញថាមពលអគ្គិសនីពីប្រទេសវៀតណាម រួមមាន៣មាត្រា។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម រដ្ឋសភា មេត្តាពិនិត្យនិងអនុម័តលើសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុនអគ្គិសនីវៀតណាមនៃសាធារណរដ្ឋសង្គមនិយមវៀតណាមសម្រាប់ការធានាលើការទិញថាមពលអគ្គិសនីពីប្រទេសវៀតណាម ដោយចាត់ទុកជាការប្រញាប់ ដោយក្តីអនុគ្រោះ។

ថ្ងៃព្រហស្បតិ៍ ៧កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២០ សប្រទ

## សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម លេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/១២២៥/០៤០ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## រាជរដ្ឋាភិបាល

ប្រគល់សិទ្ធិពេញសមត្ថភាព ជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីចុះហត្ថលេខាលើលិខិតជានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដោយអគ្គិសនីកម្ពុជា ទៅឱ្យអគ្គិសនីវៀតណាម នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ក្នុងក្របខណ្ឌនៃកិច្ចព្រមព្រៀងទិញ-លក់ថាមពលអគ្គិសនី រវាងអគ្គិសនីកម្ពុជា និងអគ្គិសនីវៀតណាម ដែលត្រូវបានចុះហត្ថលេខា នាថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៦។

ក្នុងករណីដែលឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** មានធុរៈជាយថាហេតុ ឯកឧត្តមអាចផ្ទេរសិទ្ធិនេះបាន។

ដើម្បីជាសក្ខីភាព សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយមានសិទ្ធិពេញលេញតាមអំណាចច្បាប់ដែលច្បាប់បានប្រគល់ជូន បានចុះហត្ថលេខាលើសិទ្ធិប្រទាននេះ។

ថ្ងៃសុក្រ ៩កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

ព្រះរាជាណាចក្រកម្ពុជា
*Kingdom of Cambodia*

រាជរដ្ឋាភិបាល
***Royal Government***
N° 20 DFP

ជាតិ សាសនា ព្រះមហាក្សត្រ
***Nation Religion King***

Phnom Penh, 27 March , 2026

DELEGATION OF FULL POWERS

- Having seen the Constitution of the Kingdom of Cambodia
- Having seen the Royal Decree NS/RKT/0823/1981 dated 22 August 2023 on the Appointment of the Government of the Kingdom of Cambodia
- Having seen the Royal Decree NS/RKT/0224/205 dated 21 February 2024 on the Appointment of Additional Members of the Government of the Kingdom of Cambodia
- Having seen the Royal Decree NS/RKT/0924/1169 dated 20 September 2024 on the Amendment and Appointment of Members of the Government of the Kingdom of Cambodia
- Having seen the Royal Decree NS/RKT/1124/1477 dated 20 November 2024 on the Adjustment and Supplement of the Composition of the Government of the Kingdom of Cambodia
- Having seen the Royal Kram NS/RKM/0618/012 dated 28 June 2018 promulgating the Law on the Organization and Functioning of the Council of Ministers
- Having seen the Royal Kram NS/RKM/0196/18 dated 24 January 1996 promulgating the Law on the Establishment of the Ministry of Economy and Finance
- Having seen the Royal Kram NS/RKM/1021/014 dated 15 October 2021 promulgating the Law on Investment of the Kingdom of Cambodia
- Having seen the Royal Kram NS/RKM/1225/040 dated 17 December 2025 promulgating the Law on Finance for Management of the Year 2026
- Referring to the request of the Ministry of Economy and Finance

**THE ROYAL GOVERNMENT**

Delegates herewith Full Powers to **H.E. Dr. AUN PORNMONIROTH,** Deputy Prime Minister, Minister of Economy and Finance, to sign the Governmental Guarantee of Payments by EDC to Vietnam Electricity (EVN), Socialist Republic of Vietnam, accordance with the Power Purchase Agreement between EDC and EVN dated 30 January 2026. These powers include the Powers of Delegation.

In witness whereof the undersigned, **Samdech Moha Borvor Thipadei HUN MANET,** Prime Minister of the Kingdom of Cambodia, with full powers duly entrusted to him, has signed this Delegation of Full Powers.

**Prime Minister**

**Samdech Moha Borvor Thipadei HUN MANET**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..០០១.......សហវ.......

រាជធានីភ្នំពេញ, ថ្ងៃទី ៨ ខែមេសា ឆ្នាំ២០២៦

## លិខិតធានារបស់រាជរដ្ឋាភិបាលលើការទូទាត់

**ជូនចំពោះ** ៖ **លោក** NGUYEN ANH TUAN
**ប្រធានក្រុមហ៊ុន** Vietnam Electricity ( EVN )

**អាសយដ្ឋាន** ៖ លេខ ១១, ផ្លូវ Cua Bac, ខណ្ឌ Ba Dinh,
រដ្ឋធានីហាណូយ, សាធារណរដ្ឋសង្គមនិយមវៀតណាម

**យោង** ៖

(**ក**) សិទ្ធិប្រទាន លេខ ២០ សប្រទ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦ ដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** (លិខិតសិទ្ធិប្រទាន ក្នុង ឧបសម្ព័ន្ធ១)។

(**ខ**) អគ្គិសនីកម្ពុជា ជាសហគ្រាសរដ្ឋទទួលខុសត្រូវមានកំណត់ ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ លេខ ជស/រកត/០៣៩៦/១០ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៩៦ មានការិយាល័យធំរបស់ខ្លួន តាំងនៅផ្លូវលេខ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា រាប់បញ្ចូលទាំងអ្នកបន្តវេន និងអ្នកដែលបានអនុញ្ញាតឱ្យទទួលសិទ្ធិ (**អ.ក**) ដែលបានចុះកិច្ចព្រមព្រៀងទិញ-លក់ថាមពលអគ្គិសនី (PPA) នាថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៦ ជាមួយក្រុមហ៊ុន Vietnam Electricity ( EVN ) ដែលតទៅនេះ ត្រូវហៅកាត់ថា "**ក្រុមហ៊ុន**" ។

(**គ**) រាជរដ្ឋាភិបាលកម្ពុជា យល់ព្រមផ្តល់ការធានាលើការទូទាត់ថ្លៃទិញថាមពលអគ្គិសនី ក្នុងករណីដែល អ.ក មិនធ្វើការទូទាត់។

(**ឃ**) តាមការតម្រូវក្នុងប្រការ ៨ នៃ PPA រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**ស.ហ.វ**) ជំនួសមុខឱ្យរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា (**រាជរដ្ឋាភិបាល ឬ អ្នកធានា**) បានយល់ព្រមចុះហត្ថលេខាលើលិខិតធានាលើការទូទាត់ ដោយ អ.ក ស្របតាម PPA។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

**ដូច្នេះ យើងខ្ញុំសូមធានាថា៖**

**១**. អ្នកធានា សូមធានា និងសន្យា ដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធ ទូទាត់ឱ្យក្រុមហ៊ុន នូវចំនួនទឹកប្រាក់ណាមួយ និងទាំងអស់ ដែលត្រូវបង់ និងជំពាក់ដោយ អ.ក ឱ្យក្រុមហ៊ុន ស្របតាម PPA ដែល អ.ក ខកខានពុំបានទូទាត់ អនុលោមតាមអាណត្តិ នៃ PPA។

**២**. លិខិតធានានេះ ត្រូវជាការធានាថាបន្តរហូត និងឱ្យបានសមស្រប និងត្រូវទូទាត់តុល្យការទឹកប្រាក់ ដែលត្រូវបង់ឱ្យក្រុមហ៊ុន គ្រប់ពេល ដោយ អ.ក ស្របតាម PPA ទោះជាមានលិខិតជូនដំណឹង ណាមួយ ពីការបញ្ចប់កិច្ចព្រមព្រៀង ការរំលាយ ឬអសមត្ថភាព ឬការផ្លាស់ប្តូរណាមួយ ក្នុង ព្រះរាជក្រឹត្យពាក់ព័ន្ធនឹង អ.ក ឬក្នុងនាម ឬរបៀប ឬការទូទាត់គណនីណាមួយ ឬបញ្ហាផ្សេងទៀត ក៏ដោយ។

**៣**. មុនពេលឈានដល់អនុវត្តលិខិតធានានេះ និងលើកសំណើសុំការទូទាត់ពីអ្នកធានា ក្រុមហ៊ុនត្រូវ ធ្វើសំណើជាលាយលក្ខណ៍អក្សរស្នើសុំការទូទាត់ពី អ.ក។ ក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ គិតពី កាលបរិច្ឆេទវិក្កយបត្រ ដូចមានចែងក្នុងប្រការ៩ នៃ PPA ឬសំណើសុំការទូទាត់ណាមួយពី ក្រុមហ៊ុន ទៅ អ.ក ដែលត្រូវបានទទួលដោយ អ.ក ក្រុមហ៊ុនអាចជូនដំណឹងទៅអ្នកធានាជាលាយលក្ខណ៍ អក្សរថា ការទូទាត់ដោយ អ.ក បានហួសកាលកំណត់ និងលើកសំណើសុំការទូទាត់ពីអ្នកធានា ស្របតាមលិខិតធានានេះ ហើយអ្នកធានាត្រូវធ្វើការទូទាត់ក្នុងរយៈពេល ៣០ (សាបសិប) ថ្ងៃ។ ការយឺតយ៉ាវក្នុងការទូទាត់របស់អ្នកធានាក្រោមលិខិតធានានេះ ត្រូវគិតការប្រាក់តាមអត្រាការប្រាក់ ១០% (ដប់ភាគរយ) ក្នុងមួយឆ្នាំ។ ហើយពុំមានសំណើណាមួយ ដែលបានធ្វើឡើងដោយ ក្រុមហ៊ុន ស្របតាមលិខិតធានានេះ ដែលប៉ះពាល់ ឬជំទាស់សិទ្ធិរបស់ក្រុមហ៊ុន ក្នុងការលើកសំណើបន្ថែម ឬផ្សេងទៀត ចំពោះវិក្កយប័ត្រដែលមិនទាន់បានទូទាត់ផ្សេងទៀត។ ទឹកប្រាក់ទាំងអស់ ដែលត្រូវទូទាត់ ដោយអ្នកធានា តាមលិខិតធានានេះ ត្រូវបង់ទាំងអស់ចូលក្នុងគណនីធនាគារ ដែលកំណត់ដោយ ក្រុមហ៊ុន នៅក្នុងសាធារណរដ្ឋសង្គមនិយមវៀតណាម ជាដុល្លារអាមេរិកឱ្យក្រុមហ៊ុន។

**៤**. រាល់សំណើសុំការទូទាត់ ដោយអនុលោមតាមលិខិតធានានេះ ត្រូវធ្វើឡើងតាមរយៈអ្នករត់សំបុត្រ ឬ ដោយផ្ទាល់ ដោយមន្ត្រីទទួលការអនុញ្ញាតស្របច្បាប់របស់ក្រុមហ៊ុន នៅការិយាល័យរបស់អ្នកធានា និងត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ ដែលមានចុះហត្ថលេខាដោយមន្ត្រី ដែលបានទទួលការ អនុញ្ញាតស្របច្បាប់របស់ក្រុមហ៊ុន ដោយគ្មានកាតព្វកិច្ចណាផ្សេងទៀត ដោយបញ្ជាក់ថា៖

"យើងខ្ញុំ សូមបញ្ជាក់ថា៖

(១) ក្រុមហ៊ុន Vietnam Electricity (EVN) (ក្រុមហ៊ុន) បានផ្ញើសំណើសុំការទូទាត់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អ្នកធានា) នូវទឹកប្រាក់ចំនួន .............. {បញ្ចូលទឹកប្រាក់} ដុល្លារអាមេរិក ស្របតាមចំណុចទី១ នៃលិខិតធានារបស់រាជរដ្ឋាភិបាលកម្ពុជាលើការទូទាត់ ចុះថ្ងៃទី....... ខែ........ ឆ្នាំ.......... រវាងអ្នកធានា និងក្រុមហ៊ុន។

(២) ចំនួនទឹកប្រាក់ខាងលើ គឺដល់ពេលត្រូវទូទាត់ដោយ អ.ក ស្របតាម PPA រវាង ក្រុមហ៊ុន និង អ.ក និងពុំមានផ្នែកណាមួយ នៃចំនួនទឹកប្រាក់ដែលបញ្ជាក់ខាងលើ ជាកម្មវត្ថុនៃវិវាទ រវាង អ.ក និងក្រុមហ៊ុន ទេ។

(៣) សំណើសុំការទូទាត់ពី អ.ក ជាលាយលក្ខណ៍អក្សរ បានផ្ញើរួចហើយ។

(៤) ចំនួនទឹកប្រាក់នេះ នៅពុំទាន់បានទូទាត់ដោយ អ.ក រហូតដល់ថ្ងៃនេះ។"

**៥.** អ្នកធានា សូមអះអាង និងធានា នៅថ្ងៃនេះថា៖

- អ្នកធានា មានសិទ្ធិពេញសមត្ថភាព និងការអនុញ្ញាតស្របច្បាប់ ក្នុងការទទួលកាតព្វកិច្ច ការចុះហត្ថលេខា និងការប្រគល់ ព្រមទាំងការប្រតិបត្តិ និងអង្កេត តាមអាណត្តិ និងបញ្ញត្តិនានា នៃលិខិតធានានេះ។
- លិខិតធានានេះ ជាកាតព្វកិច្ចស្របច្បាប់ មានសុពលភាព និងប្រសិទ្ធភាព និងជាឯកសារចំណង អនុលោមតាមអាណត្តិ របស់លិខិតធានានេះ។
- រាល់សកម្មភាពចាំបាច់ត្រូវបានអនុវត្ត និងរាល់ការយល់ព្រមដែលតម្រូវឱ្យមាន ត្រូវបានទទួលរួចហើយ ក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្តល់សិទ្ធិក្នុងការចុះហត្ថលេខា ការប្រគល់ និងការប្រតិបត្តិលិខិតធានានេះ។
- កាតព្វកិច្ច និងកិច្ចព្រមព្រៀងនានារបស់អ្នកធានា ក្នុងលិខិតធានានេះ ជាកាតព្វកិច្ចដោយគ្មានលក្ខខណ្ឌរបស់អ្នកធានា ដែលក្នុងការអនុវត្តកាតព្វកិច្ចទាំងនេះ ជំនឿទុកចិត្ត និងកិត្តិយសរបស់អ្នកធានាត្រូវបានប្រកាន់ខ្ជាប់។
- អ្នកធានា បានយល់ព្រមដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធថា ការចុះហត្ថលេខា និងការប្រគល់ និងការអនុវត្តដោយអ្នកធានា តាមលិខិតធានានេះ គឺជាសកម្មភាពពាណិជ្ជកម្ម មិនមែនជាសកម្មភាពសាធារណៈ ឬជាសកម្មភាពរដ្ឋាភិបាលទេ ហើយលិខិតធានានេះ ជាកាតព្វកិច្ចដោយផ្ទាល់ ដោយគ្មានលក្ខខណ្ឌ និងដោយមិនអាចបដិសេធបានឡើយ។
- ប្រសិនបើមានបណ្តឹងណាមួយចំពោះអ្នកធានា ឬចំពោះទ្រព្យសម្បត្តិរបស់អ្នកធានា ក្នុងយុត្តាធិការណាមួយ ដែលទាក់ទងនឹងលិខិតធានានេះ មិនមានអភ័យឯកសិទ្ធិណាមួយពីបណ្តឹងនោះត្រូវបានទាមទារដោយ ឬតាងនាមរបស់ខ្លួន ឬទាក់ទងទៅនឹងទ្រព្យសម្បត្តិរបស់គេ ដែលមានបច្ចុប្បន្ន ឬអាចទទួលបាននាពេលអនាគត។

៦. លិខិតធានានេះ ត្រូវមានសុពលភាព និងប្រសិទ្ធភាព ចាប់ពីកាលបរិច្ឆេទនៃ PPA រហូតដល់បញ្ចប់អាណត្តិនៃ PPA និងបន្តពេលយូរតទៅទៀត តាមចំនួនទឹកប្រាក់ជំពាក់ណាមួយ ដែល អ.ក ជំពាក់ក្រុមហ៊ុន ទាក់ទងនឹងអាណត្តិនោះ ឬនៅពុំទាន់ទូទាត់។

៧. មិនយកការខកខាន ឬការយឺតយ៉ាវណាមួយដោយក្រុមហ៊ុន ក្នុងការអនុវត្តសិទ្ធិ ឬការដោះស្រាយណាមួយ ក្រោមលិខិតធានានេះ ជាការបដិសេធសិទ្ធិ ឬការដោះស្រាយឡើយ។ គ្មានការអនុវត្តសិទ្ធិ ឬការដោះស្រាយតែមួយ ឬតែមួយផ្នែក ប្រានចោលការអនុវត្តបន្ថែមនូវសិទ្ធិផ្សេងទៀត ឬការអនុវត្តសិទ្ធិ ឬការដោះស្រាយណាមួយផ្សេងទៀតឡើយ។ ការបដិសេធរបស់ក្រុមហ៊ុន មានប្រសិទ្ធភាពលុះត្រាតែការបដិសេធនោះ ធ្វើឡើងជាលាយលក្ខណ៍អក្សរ។ សិទ្ធិ និងការដោះស្រាយនានា ដែលផ្តល់ឱ្យក្រុមហ៊ុន ដោយលិខិតធានានេះ គឺជាការផ្តល់បន្ថែម និងមិនលើកលែងសិទ្ធិ និងការដោះស្រាយដែលផ្តល់ដោយច្បាប់ឡើយ។

៨. រាល់លិខិតជូនដំណឹង ឬលិខិតឆ្លងឆ្លើយផ្សេងៗទៀត (ដែលត្រូវហៅរួមគ្នាថា "លិខិតជូនដំណឹង") ដែលត្រូវផ្តល់ ឬធ្វើឡើង ស្របតាមលិខិតធានានេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវបញ្ជូនទៅបុគ្គល និងអាសយដ្ឋាន ដូចមានបញ្ជាក់ខាងក្រោម ដោយត្រូវប្រគល់ផ្ទាល់ដៃ ឬតាមប្រៃសណីយ៍។ រាល់លិខិតជូនដំណឹង ត្រូវបានចាត់ទុកថាបានប្រគល់៖

(ក) ពេលប្រគល់ផ្ទាល់ដៃ ឬ

(ខ) នៅពេលប្រគល់ដែលមានការកត់ត្រាត្រឹមត្រូវ និងមានការបានទទួល ដោយអ្នកផ្ញើឯកសារអន្តរជាតិ ដែលមានការទទួលស្គាល់ បញ្ជូនទៅភាគីទទួល ទៅកាន់អាស័យដ្ឋានដូចមានបញ្ជាក់ខាងក្រោម (ឬក៏អាស័យដ្ឋានដទៃទៀត ដែលភាគីទទួលនោះ អាចបញ្ជាក់តាមរយៈលិខិតជូនដំណឹងឱ្យទៅភាគីប្រគល់លិខិត តាមអាស័យដ្ឋានចែងខាងក្រោម)៖

**សម្រាប់អ្នកធានា ៖**

| | | |
|---|---|---|
| ជូនចំពោះ | ៖ | ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| អាស័យដ្ឋាន | ៖ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា |
| ទូរស័ព្ទលេខ | ៖ | (៨៥៥) ២៣ ៨៩០ ៦៦៦ |

**សម្រាប់ក្រុមហ៊ុន ៖**

ជូនចំពោះ ៖ ក្រុមហ៊ុន Vietnam Electricity (EVN)

អាស័យដ្ឋាន ៖ លេខ ១១, ផ្លូវ Cua Bac, ខណ្ឌ Ba Dinh
រដ្ឋធានីហាណូយ, សាធារណរដ្ឋសង្គមនិយមវៀតណាម

ទូរស័ព្ទលេខ ៖ (០៨៤) ២៤-៦៦៩៤៦៧៨៩

ឬអាស័យដ្ឋានផ្សេងទៀត ដែលភាគីណាមួយអាចជូនដំណឹងឱ្យភាគីមួយទៀត។

៩. អ្នកជានា មិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬកាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមលិខិតជានានេះដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុន ពីក្រុមហ៊ុនឡើយ ហើយក្រុមហ៊ុនមិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬកាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមលិខិតជានានេះ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីអ្នកជានាឡើយ។ លិខិតជានានេះ ជាចំណងផ្លូវច្បាប់ និងមានអត្ថប្រយោជន៍ដល់អ្នកជានា និងក្រុមហ៊ុន ព្រមទាំងអ្នកបន្តវេន និងអ្នកទទួលសិទ្ធិស្របច្បាប់របស់ភាគីនីមួយៗ។

១០. សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជានា និងក្រុមហ៊ុន ក្រោម ឬអនុលោមតាមលិខិតជានានេះ និងអាណត្តិនៃលិខិតជានានេះ ត្រូវបានគ្រប់គ្រងដោយ និងបកស្រាយតាមច្បាប់ប្រទេសអង់គ្លេស ដែលនឹងត្រូវជាច្បាប់គ្រប់គ្រងនីតិវិធីមជ្ឈត្តនិច្ឆ័យផង។

១១. ប្រសិនបើមានវិវាទ ឬការខ្វែងគំនិតណាមួយកើតឡើង តាមរូបភាពណាក៏ដោយ ឬពាក់ព័ន្ធនឹងលិខិតជានានេះ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ បន្ទាប់ពីភាគីមួយបានទទួលសេចក្ដីជូនដំណឹងពីភាគីមួយទៀតស្ដីពីការកើតឡើងនៃវិវាទ អ្នកជានា និងក្រុមហ៊ុន ត្រូវដោះស្រាយវិវាទនោះ តាមរយៈការពិភាក្សាជាមិត្តភាព។ ប្រសិនបើ មិនអាចដោះស្រាយបានតាមរយៈការពិភាក្សាជាមិត្តភាពទេ ត្រូវដាក់វិវាទនោះទៅមជ្ឈមណ្ឌលមជ្ឈត្តនិច្ឆ័យអន្តរជាតិសឹង្ហបុរី ដើម្បីដោះស្រាយស្របទៅតាមវិធាននៃមជ្ឈមណ្ឌលមជ្ឈត្តនិច្ឆ័យអន្តរជាតិសឹង្ហបុរីនោះ។ ប្រសិនបើមានភាពមិនស្របគ្នាដោយអន្លើរវាងបញ្ញត្តិនេះ និងវិធានរបស់មជ្ឈមណ្ឌលមជ្ឈត្តនិច្ឆ័យអន្តរជាតិសឹង្ហបុរី បញ្ញត្តិនេះត្រូវមានប្រសិទ្ធភាព។ មជ្ឈត្តករត្រូវមានចំនួនបី (៣) រូប។ មជ្ឈត្តករ ត្រូវតែងតាំងស្របតាមវិធានរបស់មជ្ឈត្តនិច្ឆ័យ។ អាសនៈ ឬទីកន្លែងស្របច្បាប់នៃមជ្ឈត្តនិច្ឆ័យ គឺនៅប្រទេសសឹង្ហបុរី។ ភាសាដែលប្រើក្នុងដំណើរការមជ្ឈត្តនិច្ឆ័យ គឺភាសាអង់គ្លេស។ សេចក្ដីសម្រេចត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយគឺជាសេចក្ដីសម្រេចស្ថាពរ

និងមានប្រសិទ្ធភាពទៅលើអ្នកជានា និងក្រុមហ៊ុន និងអាចយកមកអនុវត្តនៅក្នុងតុលាការកម្ពុជាណាមួយ ដែលមានយុត្តាធិការធ្វើឱ្យសេចក្តីសម្រេចនេះអនុវត្តបាន។ ភាគីទាំងពីរ ត្រូវទទួលយក និងអនុវត្ត សេចក្តីសម្រេចនោះ ហើយភាគីនីមួយៗត្រូវទម្លាក់ចោលដោយឥតលក្ខខណ្ឌ នូវសិទ្ធិណាមួយ ដែលគេអាចមាន ដើម្បីតវ៉ាអំពីសុពលភាពនៃសេចក្តីសម្រេចនេះ ឬយុត្តាធិការនៃតុលាការមជ្ឈត្តវិនិច្ឆ័យនោះ ដើម្បីធ្វើសច្ចការឯកសារយោងណាមួយទៅមជ្ឈត្តវិនិច្ឆ័យ ដែលលិខិតជានានេះមានប្រសិទ្ធភាពអនុវត្ត។ ការទូទាត់តាមសេចក្តីសម្រេចរបស់មជ្ឈត្តវិនិច្ឆ័យ ត្រូវធ្វើឡើងជាប្រាក់ដុល្លារអាមេរិក។ ចំណាយលើមជ្ឈត្តវិនិច្ឆ័យ ត្រូវទូទាត់ដោយភាគីដែលចាញ់ក្តី លើកលែងតែមានកំណត់ផ្សេងពីនេះ ដោយតុលាការមជ្ឈត្តវិនិច្ឆ័យនោះ។ ភាគីដែលទទួលខុសត្រូវការទូទាត់តាមសេចក្តីសម្រេចរបស់មជ្ឈត្តវិនិច្ឆ័យ ត្រូវបង់ការប្រាក់តាមអត្រា ១០% (ដប់ភាគរយ) ទៅឱ្យភាគីម្ខាងទៀត នៅពេលទទួលសេចក្តីសម្រេចពីមជ្ឈត្តវិនិច្ឆ័យនោះ ដោយគិតចាប់ពីកាលបរិច្ឆេទត្រូវទូទាត់ រហូតដល់ថ្ងៃទូទាត់រួច។

**១២**. ពាក្យសរសេរជាអក្សរធំ ដែលប្រើ ប៉ុន្តែពុំមានកំណត់ន័យក្នុងលិខិតជានានេះ ត្រូវមានន័យដូចបានកំណត់នៅក្នុង PPA។

**១៣**. ប្រសិនបើបញ្ញត្តិមួយ ឬច្រើន ដែលមានក្នុងលិខិតជានានេះ ត្រូវបានរកឃើញថាគ្មានសុពលភាព ខុសច្បាប់ មិនអាចអនុវត្តបាន ឬគ្មានតម្លៃតាមផ្លូវច្បាប់ បញ្ញត្តិដទៃទៀតទាំងអស់ ត្រូវរក្សាតម្លៃតាមផ្លូវច្បាប់ ហើយភាពគ្មានសុពលភាព ភាពខុសច្បាប់ ភាពមិនអាចអនុវត្តបាន និងភាពគ្មានតម្លៃតាមផ្លូវច្បាប់ទាំងនោះ ពុំមានឥទ្ធិពលដល់សុពលភាពនៃបញ្ញត្តិផ្សេងទៀត នៃលិខិតជានានេះឡើយ។ ជាកម្មវត្ថុនៃការឯកភាពគ្នាទៅវិញទៅមក គ្មានការទូទាត់កាត់កង ការប្តឹងទាមទារទៅវិញទៅមក ការបន្ធូរបន្ថយ ឬការបន្ថយកាតព្វកិច្ចណាមួយដែលអ្នកជានាមាន ឬអាចមានចំពោះក្រុមហ៊ុន ត្រូវតែមានសម្រាប់អ្នកជានាតតាំងជាមួយក្រុមហ៊ុន ទាក់ទងនឹងកាតព្វកិច្ចណាមួយរបស់អ្នកជានា ចំពោះក្រុមហ៊ុនក្រោមលិខិតជានានេះឡើយ។

**១៤**. លិខិតជានានេះ ត្រូវផុតកំណត់នៅពេលបញ្ចប់ PPA ប្រសិនបើគ្មានការតវ៉ា ហើយនៅរក្សាការជានាតាមនេះដដែល ហេតុដូច្នេះ ការស្នើសុំជាលាយលក្ខណ៍អក្សរណាមួយ ពីក្រុមហ៊ុនជូនមកអ្នកជានា ត្រូវតែទទួលបានដោយអ្នកជានា មុនពេលផុតកំណត់នេះ។

**១៥.** លិខិតធានានេះ នឹងចូលជាធរមាន និងមានប្រសិទ្ធភាពអនុវត្ត បន្ទាប់ពីទទួលបានការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជា។

សូម **លោក** ទទួលនូវការរាប់អាន ពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងរ៉ែ និងថាមពល
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- អាជ្ញាធរអគ្គិសនីកម្ពុជា
- អគ្គិសនីកម្ពុជា
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
N°..001.........MEF/...............

Phnom Penh, 8 April 2026

## GOVERNMENT GUARANTEE OF PAYMENTS

To : **MR. NGUYEN ANH TUAN**
President and CEO of Vietnam Electricity (EVN)
Address : No. 11 Cua Bac Street, Ba Dinh Ward, Hanoi, Vietnam

Dear Sir,

We refer to:

(A) Delegation of Full Powers No. 20 DFP dated 27 March 2026, by Samdech Moha Bovor Thipadei HUN MANET, Prime Minister of the Kingdom of Cambodia (Attachment 1).

(B) ELECTRICITE DU CAMBODGE, a wholly state-owned limited enterprise incorporated by Royal Decree No. CHS/RD/0396/10 of the Royal Government of Cambodia dated 09 March 1996, with its principal office located at Street 19, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, the Kingdom of Cambodia, including its successors and permitted assignees (**EDC**) has entered into a Power Purchase Agreement (**PPA**) dated 30 January 2026 with Vietnam Electricity (EVN) hereinafter referred to as the "**Company**".

(C) The Royal Government of the Kingdom of Cambodia agrees to provide guarantee on power purchase in the event of non-payment by EDC.

(D) It is a requirement of the PPA in accordance with its Article 8, the Minister of Economy and Finance on behalf of the Royal Government of the Kingdom of Cambodia (the "**Guarantor**") has agreed to enter into this Guarantee of the payment obligations of EDC under the PPA.



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

**We hereby guarantee that:**

1. The Guarantor hereby irrevocably and unconditionally guarantees and promises to pay to the Company any and every sum of money which is due and owed by EDC to the Company under the PPA that EDC has failed to pay in accordance with the terms of the PPA.

2. This Guarantee shall be a continuing security and accordingly, shall extend to cover the balance due to the Company at any time from EDC under the PPA, notwithstanding any notice of termination or the liquidation or other incapacity or any change in Royal Decree concerning EDC or in the name or style thereof or any settlement of account or other matter whatsoever.

3. Before taking steps to enforce this Guarantee and demand payment from the Guarantor, the Company shall be obliged only to make demand in writing for payment from EDC. After sixty (60) days from the date of the invoice(s) as specified in Article 9 of the PPA or any payment demand from the Company to EDC being received by EDC, the Company may notify the Guarantor in writing that payment from EDC is overdue and make a demand for payment from the Guarantor under this Guarantee, and the Guarantor shall make payment within 30 (thirty) days of such notice. The Guarantor's late payment hereunder shall bear interest at an annual rate of ten percent (10%). And no demand made by the Company hereunder shall prejudice or restrict the right of the Company to make further or other demands against any other unpaid invoice(s). All sums payable by the Guarantor under this Guarantee shall be fully paid to the bank account designated by the Company in the Socialist Republic of Vietnam in US Dollars to the Company.

4. Any demand for payment made pursuant to this Guarantee shall be made by courier or in person by a duly authorized officer of the Company at the Guarantor's offices and shall be accompanied by a certificate signed by a duly authorized officer of the Company stating, without the obligation to substantiate, that:

   "We hereby certify that:

   (1) Vietnam Electricity (the "Company") is making this demand on the Ministry of Economy and Finance (the "Guarantor") in the amount of US Dollars................ [insert amount] in accordance with the Government Guarantee of Payments dated..............., between the Guarantor and the Company;

   (2) The amount specified above is due and payable by EDC under the PPA between the Company and EDC and no part of the amount specified above is the subject of a dispute between EDC and the Company;

(3) Demand in writing for payment from EDC has been made;

(4) Such amount, on the date hereof remains unpaid by EDC."

5. The Guarantor represents and warrants that, as of the date hereof:

- The Guarantor has full power, authority, and legal right to incur the obligation, to execute and deliver, and to perform and observe the terms and provisions of this Guarantee.
- This Guarantee constitutes legal, valid, binding, and enforceable obligations of the Guarantor in accordance with its terms.
- All necessary action has been taken, and all approvals required have been obtained, under the laws of the Kingdom of Cambodia to authorize the execution, delivery, and performance of this Guarantee.
- The obligations and covenants of the Guarantor in this Guarantee constitute unconditional obligations of the Guarantor, for the performance of which the full faith and credit of the Guarantor is pledged.
- The Guarantor unconditionally and irrevocably agrees that the execution, delivery, and performance by it of this Guarantee constitute commercial acts rather than public or governmental acts and such Guarantee constitutes our unconditional and irrevocable direct obligation.
- Should any proceedings be brought against it or its assets in any jurisdiction in relation to this Guarantee, no immunity from such proceedings shall be claimed by or on its behalf or with respect to its assets which it now has or may acquire in the future.

6. This Guarantee shall remain in full force and effect from the date of the PPA until the termination of the term of the PPA and for so long thereafter as any amount owed to the Company by EDC in connection with such term is or may be outstanding.

7. No failure or delay by the Company to exercise any right or remedy under this Guarantee shall constitute a waiver of that right or remedy. No single or partial exercise of any right or remedy shall preclude any other or further exercise thereof or the exercise of any other right or remedy. No waiver by the Company shall be effective unless it is in writing. The rights and remedies of the Company provided by this Guarantee are cumulative and not exclusive of any rights or remedies provided by law.

8. All notices or other communications (together "Notices") to be given or made hereunder shall be in writing, shall be addressed for the attention of the person indicated below and shall be delivered personally or by courier. All Notices shall be deemed delivered:

   (a) when presented personally, or

   (b) upon the delivery of duly recorded and receipted delivery by a recognized international document courier, addressed to the receiving Party, at the address indicated below (or such other address as such Party may have specified by notice delivered to the delivering Party at its address specified below).

The address for service of Notice shall be:

For the Guarantor:

| | | |
|---|---|---|
| Attention | : | Minister, Ministry of Economy and Finance |
| Address | : | Ministry of Economy and Finance<br>Street No.92, Sangkat Wat Phnom,<br>Khan Daun Penh, Phnom Penh, Kingdom of Cambodia |
| Tel. | : | (855) 23 890 666 |

For the Company:

| | | |
|---|---|---|
| Attention | : | The President and CEO of Vietnam Electricity (EVN) |
| Address | : | No. 11, Cua Bac Street, Ba Dinh Ward, Hanoi, Vietnam |
| Tel. | : | (084) 24-66946789 |

or such other addresses as either Party may have notified to the other Party.

9. The Guarantor shall not assign or transfer all or any part of its rights or obligations hereunder without the prior written consent of the Company, and the Company shall not assign or transfer all or any part of its rights or obligations hereunder without the prior written consent of the Guarantor. This Guarantee shall be binding upon and inure to the benefit of the Guarantor and the Company and the respective successors and permitted assignees of each Party.

10. The rights and obligations of the Guarantor and the Company under or pursuant to this Guarantee and the terms of this Guarantee shall be governed by and construed according to the English Laws, which shall also be the procedural law governing any arbitration.

11. If there is any dispute or difference of any kind whatsoever arising out of or in connection with this Guarantee, the Guarantor and the Company shall attempt for a period of thirty (30) days after the receipt by one Party of a notice from the other Party of the existence of the dispute to settle

such dispute through mutual amicable discussions. If such dispute cannot be resolved through mutual amicable discussions, then it shall be submitted to the Singapore International Arbitration Centre for arbitration in accordance with the arbitration rules of the Singapore International Arbitration Centre. And if there are discrepancies between this clause and the rules of the Singapore International Arbitration Centre, this clause shall govern. The number of arbitrators shall be three (3). The arbitrators shall be appointed in accordance with the rules. The seat, or legal place of arbitration, shall be Singapore. The language used in the arbitral proceedings shall be English. The award rendered shall be in writing and shall be final, conclusive and binding upon the Guarantor and the Company and award thereon may be entered in any Cambodian court having jurisdiction for its enforcement. The Parties shall execute and perform the award and each Party hereby irrevocably waives any right it may have to contest the validity of such award or the jurisdiction of the arbitration tribunal to hear any reference to arbitration to which this Guarantee applies. Any payment under an arbitration award shall be payable in U.S. Dollars. The costs of arbitration shall be borne by the losing Party, unless otherwise determined by the arbitration tribunal. The Party that is responsible to pay any amount in accordance with an arbitration award shall pay interest at a rate of ten percent (10%) to the other Party in receipt of such arbitration award from the due date for the payment of such award until the date of payment of such award.

12. The capitalized terms used but not defined in this Guarantee shall have the meanings given to them in the Power Purchase Agreement.

13. If one or more provisions contained in this Guarantee is held or found to be invalid, illegal, or unenforceable in any respect, all other provision(s) shall be given effect to the extent permitted by law and the invalidity, illegality, or unenforceability of any provision shall not affect the validity of the remaining provisions of this Guarantee. Subject to mutual agreement, no set-off, counterclaim, reduction, or diminution of any obligation that the Guarantor has or may have against the Company shall be available to the Guarantor against the Company in connection with any obligation of the Guarantor to the Company under this Guarantee.

14. This Guarantee shall expire upon the termination of the PPA if no claim has been made and remains outstanding hereunder and any written demand made to us by you hereunder must therefore be received by us before that time.

14. This Guarantee shall expire upon the termination of the PPA if no claim has been made and remains outstanding hereunder and any written demand made to us by you hereunder must therefore be received by us before that time.

15. This Guarantee shall be in full force and effect on its ratification by legislatures of the Kingdom of Cambodia.

Yours sincerely,

**Dr. AUN PORNMONIROTH**
DEPUTY PRIME MINISTER, MINISTER,
MINISTRY OF ECONOMY AND FINANCE

CC:
- Ministry of Royal Palace
- Secretariat of Senate
- Secretariat of National Assembly
- Office of Council of Ministers
- Ministry of Foreign Affairs and International Cooperation
- Ministry of Mines, and Energy
- Council for the Development of Cambodia (CDC)
- Cabinet of Semdech Moha Bovor Thipadei HUN MANET, Prime Minister of the Kingdom of Cambodia
- Electricity Authority of Cambodia (EAC)
- Electricite du Cambodge (EDC)
- File

# ព្រះរាជក្រឹត្យ

នស/រកត/០៥២៦/៥៨៣

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០២៣/០១៩ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអធិការកិច្ច
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងមុខតំណែង នៅក្រសួងអធិការកិច្ច ដល់មន្ត្រីរាជការ **០៣ រូបៈ**

| | |
|---|---|
| ១- ឯកឧត្តម **ឡុក ស៊ីណា** | អត្តលេខ **១៧៣២០០០០០៥** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៣ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជាអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ |
| ២- ឯកឧត្តម **អូន ម៉េងឈាន់** | អត្តលេខ **១៧៥០៨០០០២៤** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៣ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជាអគ្គនាយក នៃអគ្គនាយកដ្ឋានអធិការកិច្ច |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៣- ឯកឧត្តម **សោម បូរ៉ាន់** អត្តលេខ ១៧២០២០០០០៨ ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៤ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជាអគ្គនាយក នៃអគ្គនាយកដ្ឋានដោះស្រាយបណ្តឹង។

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៦

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបន្ទូលបង្គាប់**

**ប្រមុខរដ្ឋស្តីទី**

៧ភសៈ ២៦០៥-៥៩១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់សុី**

# ព្រះរាជក្រឹត្យ

នស/រកត/០៥២៦/៥៨៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំនិងលើកផែនការដើម្បីធ្វើសមាហរណកម្មមន្ត្រីរាជការបច្ចុប្បន្ននៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន និងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតបឋម ទៅក្នុងក្របខ័ណ្ឌនៃអង្គគ្រូបង្រៀននៃព្រះរាជក្រឹត្យនេះ ជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច។

**មាត្រា៥៦ .-**

មន្ត្រីរាជការក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន និងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតបឋម ដែលមិនត្រូវបានធ្វើសមាហរណកម្មទៅក្នុងលក្ខន្តិកៈនៃអង្គគ្រូបង្រៀនដែលកំណត់ដោយព្រះរាជក្រឹត្យនេះ ត្រូវបន្តស្ថិតក្រោមព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន ព្រះរាជក្រឹត្យលេខ នស/រកត/០៩០១/៣៤១ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតបឋម។

## ជំពូកទី១០

## អន្តរប្បញ្ញត្តិ

**មាត្រា៥៧ .-**

លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន ព្រះរាជក្រឹត្យលេខ នស/រកត/០៩០១/៣៤១ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតបឋម ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តជំនួស ស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី១១

## អវសានប្បញ្ញត្តិ

**មាត្រា៥៨ .-**

ព្រះរាជក្រឹត្យនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៧ តទៅ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៩ .-**

សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ *សៅរ៍ ១៤ កើត* ខែ *ជេស្ឋ* ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី *៣០* ខែ *ឧសភា* ឆ្នាំ២០២៦

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាសប្តាប់**

**ប្រមុខរដ្ឋស្តីទី**

*ពរម. ៤៦០៥. ៦០៤*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

Thorany

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០៦២៦/៥៩៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោធិសាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តាំងស៊ប់ក្នុងក្របខ័ណ្ឌដល់លោក **ឈួរ ពន្លឺ** ទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ ៤ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្តីការគណៈរដ្ឋមន្ត្រី ចាប់ពីថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៦។

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០២៦

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ចារ. ៥៦០៦. ៦០៤

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានឃើញ និងត្រឹមត្រូវតាមច្បាប់ដើម
**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

**បណ្ឌិតសភាចារ្យ ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០៦២៦/៥៨៦

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** បន្ថយឋានន្តរស័ក្តិ ពី ឧត្តមសេនីយ៍ទោ ឱ្យមកនៅត្រឹមថ្នាក់ ឧត្តមសេនីយ៍ត្រី នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ២រូបៈ

១- ឧត្តមសេនីយ៍ទោ ហេង សារឿន អត្តលេខ ០៥៦២៥
២- ឧត្តមសេនីយ៍ទោ អ៊ុក ណារិន អត្តលេខ ៣៦១៤២។

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០២៦
**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ពរស. ២៦០៦. ៦០៥

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់សុី**

# ព្រះរាជក្រឹត្យ

នស/រកត/០៦២៦/៥៩៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សម្ពោធិសាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០២៣/០១៩ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអធិការកិច្ច
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១២៣/០២០ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ROYAUME DU CAMBODGE ★ LE MINISTRE DU PALAIS ROYAL

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ NS/KRT-34 ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៩៦ ត្រាស់បង្គាប់បង្កើតក្រសួងព្រះបរមរាជវាំង
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២២៣/២៥៦៤ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ទ្រង់ត្រាស់បង្គាប់

**មាត្រា១** : ដាក់ឱ្យចូលនិវត្តន៍មុនអាយុកំណត់ដល់លោក **ម៉ិន ឬទ្ធី** នៅក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ **៦** នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងមុខងារសាធារណៈ តាមការស្នើសុំរបស់សាមីខ្លួនចាប់ពីថ្ងៃទី**១** ខែ**មីនា** ឆ្នាំ**២០២៦**។

**មាត្រា២** : ដាក់ឱ្យចូលនិវត្តន៍ដល់មន្ត្រីរាជការ **១៨២ រូប** នៅក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ឋានន្តរស័ក្តិឧត្តមមន្ត្រីការបរទេស នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម នៅក្រសួង ស្ថាប័នចំនួន **២៩**៖

| **ល.រ** | **គោត្តនាម និងនាម** | **ឋានន្តរស័ក្តិ និងថ្នាក់** | **ថ្ងៃខែឆ្នាំចូលនិវត្តន៍** |
|---|---|---|---|
| **[illegible]ក្រសួង[illegible]សិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | | | |
| [illegible] | [illegible]ក ឧ[illegible] **[illegible]ន ឆាយ** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ០៤/០៩/២០២៦ |
| [illegible] | [illegible]ក **[illegible]នុធ្វីរ៉ា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ១ | ២៣/១០/២០២៦ |

| | | | |
|---|---|---|---|
| ៣ | លោក **ម៉ុច ចន្ថា** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ០២/០៨/២០២៦ |
| ៤ | លោក **ឈាង សុធី** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ០២/១០/២០២៦ |
| ៥ | លោក **ម៉ុល ចាន់ថា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ១ | ០៩/១០/២០២៦ |
| ៦ | ឯកឧត្តម **ពុំ សុថា** | ឧត្តមមន្ត្រី ថ្នាក់លេខ ២ | ១១/០៨/២០២៦ |
| ៧ | លោកស្រី **គីម លក្ខិណា** | ឧត្តមមន្ត្រី ថ្នាក់លេខ ២ | ០៤/១០/២០២៦ |
| ៨ | លោកស្រី **សាខន សុផានី** | ឧត្តមមន្ត្រី ថ្នាក់លេខ ២ | ០៦/០៨/២០២៦ |
| ៩ | លោក **ហេង ចំរើន** | ឧត្តមមន្ត្រី ថ្នាក់លេខ ២ | ០៧/០៧/២០២៦ |
| ១០ | លោកស្រី **ព្រុំ ធីតា** | ឧត្តមមន្ត្រី ថ្នាក់លេខ ២ | ២៥/០៧/២០២៦ |
| ១១ | លោក **ថោង ថាន់ទីវ៉ាឌុឌ្ឍី** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ២ | ៣០/០៩/២០២៦ |
| ១២ | លោក **ហង់ សុខហៀង** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ២ | ០៩/១០/២០២៦ |
| ១៣ | លោក **សំ សារុន** | ឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ០២/០៧/២០២៦ |
| ១៤ | លោក **គង់ ថា** | ឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ០២/១០/២០២៦ |
| ១៥ | លោក **គន់ ច័ន្ទតារ៉ា** | ឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ២០/០៩/២០២៦ |
| ១៦ | លោកស្រី **ថុន ធីតា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៣ | ០៨/០៨/២០២៦ |
| ១៧ | លោក **នេត វណ្ណារ៉ា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៣ | ១៦/១២/២០២៦ |
| ១៨ | លោក **អ៊ូ សោភ័ណ** | ឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ០៧/០៩/២០២៦ |
| ១៩ | លោក **គិត ប៊ុណ្ណា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៣ | ០៧/១០/២០២៦ |
| ២០ | លោក **សោម សម្បត្តិ** | ឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ០៥/០៨/២០២៦ |
| ២១ | លោក **អៀង សុខឌឿន** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៤ | ១៦/១០/២០២៦ |
| ២២ | លោក **ពេជ ផល្លី** | ឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ១២/១២/២០២៦ |
| ២៣ | លោក **យូ ភាណាវិមាន** | ឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ១៧/០៨/២០២៦ |
| ២៤ | លោក **ស៊ិន វ៉ាឌុធ** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៤ | ១២/១២/២០២៦ |
| ២៥ | លោក **ហ៊ី ខ្សៃ** | ឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ៣០/០៨/២០២៦ |
| ២៦ | លោក **សុខ សុខ** | ឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ១៥/០៩/២០២៦ |
| ២៧ | លោក **ហៀង ហ៊ាញ** | ឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ២៧/០៨/២០២៦ |
| ២៨ | លោក **ជា ថារិទ្ធ** | ឧត្តមមន្ត្រី ថ្នាក់លេខ ៥ | ០៥/១០/២០២៦ |
| ២៩ | លោកស្រី **ម៉ៅ សាប៊ីណា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៥ | ៣០/១២/២០២៦ |
| ៣០ | លោក **ហោ ប៉ូលី** | ឧត្តមមន្ត្រី ថ្នាក់លេខ ៥ | ១៤/០៩/២០២៦ |
| ៣១ | លោក **ហ៊ុន ស៊ីថា** | ឧត្តមមន្ត្រី ថ្នាក់លេខ ៥ | ០៧/១២/២០២៦ |
| ៣២ | លោក **អ៊ឹង វណ្ណមុនី** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៥ | ១៨/០៨/២០២៦ |
| ៣៣ | [illegible] **[illegible]ី សុផល** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៥ | ១១/០៨/២០២៦ |
| [illegible] | លោក **[illegible] សីលា** | ឧត្តមមន្ត្រី ថ្នាក់លេខ ៥ | ១០/០៨/២០២៦ |
| [illegible] | លោក **[illegible] ផល្លា** | ឧត្តមមន្ត្រី ថ្នាក់លេខ ៥ | ១៧/០៧/២០២៦ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

| | | | |
|---|---|---|---|
| ៣៦ | លោក **នៅ ផុង** | ឧត្តមមន្ត្រី ថ្នាក់លេខ ៦ | ០១/០៩/២០២៦ |
| ៣៧ | លោកស្រី **សេង មិចរ៉ាមី** | ឧត្តមមន្ត្រី ថ្នាក់លេខ ៦ | ០២/១១/២០២៦ |
| ៣៨ | លោក **ជ វ៉ាងលី** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៦ | ០៥/១១/២០២៦ |
| **២-ក្រសួងអធិការកិច្ច** | | | |
| ១ | លោក **នី ម៉ូណោ** | ឧត្តមមន្ត្រី ថ្នាក់លេខ ២ | ១៩/០៩/២០២៦ |
| ២ | លោក **ស៊ិន សុប្រីយ៉ានី** | ឧត្តមមន្ត្រី ថ្នាក់លេខ ២ | ០១/១១/២០២៦ |
| ៣ | លោក **ជា សុវណ្ណគីរី** | ឧត្តមមន្ត្រី ថ្នាក់លេខ ៦ | ០៤/០៩/២០២៦ |
| **៣-រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល** | | | |
| ១ | លោក **វ៉ាន់ ណូរ៉ាក់** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ០៦/១២/២០២៦ |
| ២ | លោក **សុខ សារិន** | ឧត្តមមន្ត្រី ថ្នាក់លេខ ២ | ០៤/១២/២០២៦ |
| **៤-ក្រសួងមុខងារសាធារណៈ** | | | |
| ១ | លោកស្រី **សូ ថាគា** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ០១/១២/២០២៦ |
| ២ | លោក **មិន សុដានី** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ០៨/០៨/២០២៦ |
| ៣ | លោក **អ៊ុង ណារឿង** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ១០/១១/២០២៦ |
| ៤ | លោក **គង់ចន្ទសីហ៍វិសាល** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ០៧/០៧/២០២៦ |
| ៥ | លោក **អ៊ុន សុខា** | ឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ១៥/០៨/២០២៦ |
| **៥-ក្រសួងពាណិជ្ជកម្ម** | | | |
| ១ | លោក **ជា វេង** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ២០/១១/២០២៦ |
| ២ | លោកស្រី **កែវ វី** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ២ | ២២/០៩/២០២៦ |
| ៣ | លោក **ជា ម៉ិច** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ២ | ០៨/០៩/២០២៦ |
| ៤ | លោក **ពេជ ច័ន្ទ** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៣ | ១៦/០៧/២០២៦ |
| ៥ | លោក **ចាន់ ថុន** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៣ | ០៥/១០/២០២៦ |
| ៦ | លោក **ឡូន ធឿន** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៣ | ១៥/១១/២០២៦ |
| ៧ | លោក **ច្រាយ ហុងអៃ** | ឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ១៣/០៩/២០២៦ |
| ៨ | លោក **សម សុធា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៥ | ០៨/១២/២០២៦ |
| **៦-ទីស្តីការគណៈរដ្ឋមន្ត្រី** | | | |
| ១ | ឯកឧត្តម **សួស វិសុទ្ធ** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ១១/០៨/២០២៦ |
| ២ | ឯកឧត្តម **ស៊ុំ ឈុំឡុង** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ១៨/០៩/២០២៦ |
| ៣ | លោក **ឯក សុខន** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ០៥/០៩/២០២៦ |
| ៤ | លោក **សូ សុធីរ** | ឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ២៥/០៨/២០២៦ |
| ៥ | លោក **អៀង មុនី** | ឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ០៣/១១/២០២៦ |
| **៧-ក្រសួងធម្មការ និងសាសនា** | | | |
| [illegible] | លោក **[illegible]ង វណ្ណៈ** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ១១/១០/២០២៦ |
| [illegible] | លោក **វណ្ណ ម៉ិនណា** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ១២/១១/២០២៦ |



ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

| | | | |
|---|---|---|---|
| **៨-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** | | | |
| ១ | លោក **ឱក ប៊ុណ្ណារ័ត្ន** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៣ | ០៥/១១/២០២៦ |
| ២ | លោក **ព្រាំ សំអាន** | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៣ | ១៣/០៨/២០២៦ |
| ៣ | លោក **គង់ មរកត** | ឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ២៨/១០/២០២៦ |
| **៩-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | | | |
| ១ | លោក **ពៅ ធី** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ១ | ១៥/០៧/២០២៦ |
| ២ | លោក **ហេង កុសលបុត្រ** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ០១/០៩/២០២៦ |
| ៣ | លោក **គិច សៀកឧន** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ១៧/១១/២០២៦ |
| ៤ | លោក **កុយ ចាន់ដារិទ្ធ** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ២០/០៨/២០២៦ |
| ៥ | លោក **ម៉ុក ឃួត** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ១២/១២/២០២៦ |
| ៦ | លោក **ស៊ុនលី ជីនី** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ០១/០៩/២០២៦ |
| ៧ | លោក **ឡេង ណាងឈី** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ២០/០៩/២០២៦ |
| ៨ | លោក **ពុធ សុខា** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ០៩/០៨/២០២៦ |
| ៩ | លោក **សារឹម សារ៉ាន់** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ១៤/០៨/២០២៦ |
| ១០ | លោក **តែម មុនីបុត្រ** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ១១/១២/២០២៦ |
| ១១ | លោកស្រី **សំរិទ្ធ សុរិយា** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ២០/១២/២០២៦ |
| ១២ | លោក **តិត្យ ចិន្ធូ** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ២៥/០៨/២០២៦ |
| ១៣ | លោក **ស្រេង សំណាង** | ឧត្តមមន្ត្រី ថ្នាក់លេខ ២ | ១៩/០៧/២០២៦ |
| ១៤ | លោកស្រី **ចាន់ ស៊ីថា** | ឧត្តមមន្ត្រី ថ្នាក់លេខ ២ | ២៥/០៩/២០២៦ |
| ១៥ | លោក **ស្រេង ម៉ន** | ឧត្តមមន្ត្រី ថ្នាក់លេខ ២ | ១៣/០៧/២០២៦ |
| ១៦ | លោកស្រី **កែវ ច័ន្ទតារា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ២ | ១០/១១/២០២៦ |
| ១៧ | លោក **គង់ សុគន្ធ** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ២ | ១២/០៧/២០២៦ |
| ១៨ | ឯកឧត្តម **យូ គិរមៀ** | ឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ០១/០៧/២០២៦ |
| ១៩ | លោកស្រី **ឃឹម ដារីយ៉ា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៣ | ១៥/០៩/២០២៦ |
| ២០ | លោក **ម៉ូ សំអាង** | ឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ២៤/០៧/២០២៦ |
| ២១ | លោក **ហាំ ណារិទ្ធ** | ឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ១៥/០៨/២០២៦ |
| ២២ | លោក **៦ម រ៉ូនី** | ឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ១៨/១១/២០២៦ |
| ២៣ | លោក **ឆៃ ប៊ុនឈន** | ឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ១៧/១២/២០២៦ |
| ២៤ | លោក **ឈួរ សុភាព** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៤ | ២៥/០៨/២០២៦ |
| ២៥ | លោក **ទូច សុខគិរិន្ទ** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៤ | ១១/០៩/២០២៦ |
| [illegible] | [illegible]ស្រី **សេង សារិទ្ធ** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៤ | ១០/១២/២០២៦ |
| [illegible] | [illegible]ក **[illegible] ស៊ីន** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៤ | ០២/១០/២០២៦ |
| [illegible] | [illegible] **[illegible] ហុកស៊ី** | ឧត្តមមន្ត្រី ថ្នាក់លេខ ៥ | ០៧/០៧/២០២៦ |

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

| | | | |
|---|---|---|---|
| ២៩ | លោក **ម៉ែន ណារ៉េត** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៥ | ៣១/១២/២០២៦ |
| ៣០ | លោក **ឈីម សារ៉ាឌុធ** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៥ | ០៩/០៩/២០២៦ |
| ៣១ | លោក **ថៃ តុង** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៥ | ២៩/០៨/២០២៦ |
| ៣២ | លោក **អ៊ឹម លក្ខិណា** | ឧត្តមមន្ត្រី ថ្នាក់លេខ ៦ | ០៦/១២/២០២៦ |
| **១០-ក្រសួងបរិស្ថាន** | | | |
| ១ | ឯកឧត្តម **ចាយ សាមិត្ត** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ០៥/០៩/២០២៦ |
| ២ | ឯកឧត្តម **ស៊ី រ៉ាមុនី** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ២០/១២/២០២៦ |
| ៣ | លោក **ឈុន ប៊ុនលី** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ១៥/១០/២០២៦ |
| ៤ | លោកស្រី **នុត សុសីលា** | ឧត្តមមន្ត្រី ថ្នាក់លេខ ២ | ២១/០៨/២០២៦ |
| ៥ | លោក **តាំង គ្រុយ** | ឧត្តមមន្ត្រី ថ្នាក់លេខ ២ | ១៥/១០/២០២៦ |
| ៦ | លោកស្រី **មាន សុខអូន** | ឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ០៥/០៩/២០២៦ |
| **១១-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** | | | |
| ១ | លោក **ឈុន វីរ៉ា** | ឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៣ | ២៤/០៨/២០២៦ |
| ២ | លោក **ឆួក ប៊ុនធៃល** | ឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៣ | ១០/០៨/២០២៦ |
| ៣ | លោកស្រី **ឌី យឿន** | ឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៤ | ១៥/១០/២០២៦ |
| **១២-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** | | | |
| ១ | ឯកឧត្តម **ឃុត ឧត្យារិទ្ធ** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ២២/០៧/២០២៦ |
| ២ | លោក **ប៊ី ពិទូរ្យ** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ១ | ១៥/១២/២០២៦ |
| ៣ | លោក **ហួត វណ្ណធូ** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ២២/១២/២០២៦ |
| ៤ | លោក **វៀង សុម៉ាន់** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ១ | ១០/១២/២០២៦ |
| ៥ | លោក **ប្រាក់ ចន្ទរ័ត្ន** | ឧត្តមមន្ត្រី ថ្នាក់លេខ ២ | ០៦/០៨/២០២៦ |
| ៦ | លោកស្រី **ជិន គេសរ** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ២ | ២៧/១០/២០២៦ |
| ៧ | លោកស្រី **ជុំ សុផា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៣ | ២០/១០/២០២៦ |
| ៨ | លោក **សុខ ណារិទ្ធ** | ឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ០៣/១២/២០២៦ |
| ៩ | លោក **អោក សំអុល** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៤ | ០៨/១២/២០២៦ |
| ១០ | លោក **ទ្រី សាយ** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៤ | ០១/០៩/២០២៦ |
| **១៣-ក្រសួងព័ត៌មាន** | | | |
| ១ | លោក **យូ សំបូរ** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ០៥/០៩/២០២៦ |
| ២ | លោក **សាត សុផល** | ឧត្តមមន្ត្រី ថ្នាក់លេខ ២ | ២៣/១២/២០២៦ |
| ៣ | លោក **ទូច លាង** | ឧត្តមមន្ត្រី ថ្នាក់លេខ ២ | ២៨/០៨/២០២៦ |
| ៤ | លោក **ហែម បូរិន** | ឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ០១/១០/២០២៦ |
| **[illegible]-ក្រសួងមហាផ្ទៃ** | | | |
| ១ | លោក **សំ ប៊ុណ្ណារិន** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ០៩/១២/២០២៦ |

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

| | | | |
|---|---|---|---|
| ២ | លោក **ឈួន គឹមសាន** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ៣០/១២/២០២៦ |
| ៣ | លោក **នាក់ ណោរ៉ុន** | ឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ១៧/១០/២០២៦ |
| ៤ | លោក **យស យុទ្ធី** | ឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ០១/១០/២០២៦ |
| ៥ | លោក **ស សុគន្ធ** | ឧត្តមមន្ត្រី ថ្នាក់លេខ ៦ | ១០/០៩/២០២៦ |
| **១៥-ក្រសួងយុត្តិធម៌** | | | |
| ១ | ឯកឧត្តម **ជីវ សុខហាក់** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ០៦/១២/២០២៦ |
| ២ | លោកស្រី **ឃុត សុគន្ធា** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ១៦/០៩/២០២៦ |
| ៣ | លោកស្រី **មុិច សុជាតា** | ឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ១២/១២/២០២៦ |
| ៤ | លោក **ឈាវ រិនឌី** | ឧត្តមមន្ត្រី ថ្នាក់លេខ ៥ | ១២/១២/២០២៦ |
| ៥ | លោកស្រី **មុិច ស៊ីហ៊ីន** | ឧត្តមមន្ត្រី ថ្នាក់លេខ ៥ | ១០/១១/២០២៦ |
| **១៦-ក្រសួងផែនការ** | | | |
| ១ | លោក **អឿ សុផល** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ១៧/០៧/២០២៦ |
| ២ | លោក **ហាក់ សុធារ៉ា** | ឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ០៣/០៨/២០២៦ |
| ៣ | លោក **សុខ បូរិទ្ធ** | ឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ១៧/០៨/២០២៦ |
| ៤ | លោក **កែវ បុប្ផា** | ឧត្តមមន្ត្រី ថ្នាក់លេខ ៥ | ១៨/១២/២០២៦ |
| **១៧-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** | | | |
| ១ | លោក **ទូច ឧុទ្ធី** | ឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ៣០/០៧/២០២៦ |
| ២ | លោកជំទាវ **ទេព រ៉ូដា** | ឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ២០/១០/២០២៦ |
| **១៨-ក្រសួងសាធារណការ និងដឹកជញ្ជូន** | | | |
| ១ | ឯកឧត្តម **សួង ហេង** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ១ | ០២/១០/២០២៦ |
| ២ | លោក **ថុន ឆដា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ២ | ២៧/០៧/២០២៦ |
| ៣ | លោក **សេង សុធារដ្ឋ** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៣ | ២២/១០/២០២៦ |
| ៤ | លោក **ហេង មុិនលី** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៣ | ០៤/១២/២០២៦ |
| ៥ | លោក **ម៉ែន រដ្ឋា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៣ | ១៧/០៧/២០២៦ |
| ៦ | លោក **មុឺន សុវណ្ណានី** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៣ | ១៧/០៩/២០២៦ |
| ៧ | លោក **រំ សុវិជ្ជា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៣ | ១៧/១១/២០២៦ |
| ៨ | លោក **ច្រឹង សុភចារដ្ឋ** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៤ | ២៥/១២/២០២៦ |
| ៩ | លោក **អ៊ូ សារ៉េត** | ឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ១៦/០៩/២០២៦ |
| ១០ | លោក **ឡុក សាខុន** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៤ | ១៥/០៨/២០២៦ |
| ១១ | លោក **ជ័យ ធឿន** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៤ | ១០/១១/២០២៦ |
| [illegible] | [illegible] **ញ៉ៀម សារមេត្ត** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៥ | ២៧/១០/២០២៦ |
| [illegible] | លោ[illegible] **[illegible]ជត ច័ន្ទតារា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៥ | ២៧/១២/២០២៦ |
| [illegible] | [illegible] **[illegible] ណារិន** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៦ | ១៦/០៨/២០២៦ |

| | | | |
|---|---|---|---|
| **១៩-ក្រសួងព្រះបរមរាជវាំង** | | | |
| ១ | ឯកឧត្តម **ម៉ែន ឧុទ្ធី** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ១៧/១២/២០២៦ |
| **២០-ក្រសួងអភិវឌ្ឍន៍ជនបទ** | | | |
| ១ | លោក **សុក សុផល្លី** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ០៨/០៩/២០២៦ |
| ២ | ឯកឧត្តម **អ៊ឹង វណ្ណា** | ឧត្តមមន្ត្រី ថ្នាក់លេខ ២ | ២២/០៧/២០២៦ |
| ៣ | លោក **តាន់ វណ្ណារី** | ឧត្តមមន្ត្រី ថ្នាក់លេខ ២ | ១២/១២/២០២៦ |
| ៤ | លោក **ចាន់ សុវណ្ណារ៉ា** | ឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ១០/១០/២០២៦ |
| **២១-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | | | |
| ១ | លោក **ចាន់ សាម៉េង** | ឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ១៦/១០/២០២៦ |
| **២២-ក្រសួងទេសចរណ៍** | | | |
| ១ | ឯកឧត្តម **ឱក តារារិទ្ធិ** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ៣០/១២/២០២៦ |
| ២ | លោក **ធិម សេរីវុឌ្ឍ** | ឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ១១/១១/២០២៦ |
| ៣ | លោក **ទេព ហ៊ី** | ឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ១២/០៨/២០២៦ |
| **២៣-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** | | | |
| ១ | ឯកឧត្តម **សរ សុវណ្ណា** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ១០/១០/២០២៦ |
| ២ | ឯកឧត្តម **មាន ច័ន្ទវ៉ាន់នី** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ១៥/០៧/២០២៦ |
| ៣ | លោក **ស៊ឹង សុច្ចរ៉ា** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ០៤/១២/២០២៦ |
| ៤ | លោក **យិន ចាន់សុជាតិ** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ១៣/០៧/២០២៦ |
| ៥ | លោក **ភាគ៌ម សុណាវិន** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៣ | ១៩/១២/២០២៦ |
| ៦ | លោក **ប៊ិល វ៉ានី** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៥ | ០៥/០៨/២០២៦ |
| ៧ | លោក **គង់ ចាន់ថន** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៦ | ១២/១២/២០២៦ |
| **២៤-ក្រសួងធនធានទឹក និង ឧតុនិយម** | | | |
| ១ | លោក **ស្វាយ សុគន្ធី** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ១០/១០/២០២៦ |
| ២ | លោក **តាន់ អិត** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ០១/១០/២០២៦ |
| ៣ | ឯកឧត្តម **គឹម សីហា** | ឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ១៨/០៨/២០២៦ |
| ៤ | លោក **ដួង សំអាង** | ឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ២៥/១១/២០២៦ |
| ៥ | លោក **យិន សុវណ្ណា** | ឧត្តមមន្ត្រី ថ្នាក់លេខ ៥ | ១៣/១០/២០២៦ |
| **២៥-ក្រសួងកិច្ចការនារី** | | | |
| ១ | លោកស្រី **ស៊ិន ស៊ីផាន** | ឧត្តមមន្ត្រី ថ្នាក់លេខ ៥ | ០៩/០៨/២០២៦ |
| ២ | លោកស្រី **តូច សុណាវី** | ឧត្តមមន្ត្រី ថ្នាក់លេខ ៥ | ១៨/១២/២០២៦ |
| **២៦-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** | | | |
| ១ | ឯកឧត្តម **ភុយ ទេពដារាវុធ** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ១១/០៧/២០២៦ |
| [illegible] | [illegible]ស្រី **ហ៊ី សុគន្ធវារី** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ០៧/០៩/២០២៦ |
| **[illegible]ង្គភាពប្រឆាំងអំពើពុករលួយ** | | | |
| [illegible] | [illegible]ឧត្តម **[illegible]ហាង សុខឃៀង** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ២៦/០៩/២០២៦ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

| | | | |
|---|---|---|---|
| ២ | ឯកឧត្តម **ស៊ិន ម៉ៃឌ្យ៉ា** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ២១/០៧/២០២៦ |
| **២៨-ក្រសួងរ៉ែ និងថាមពល** | | | |
| ១ | ឯកឧត្តម **ឈុំ ប៊ុណ្ណារិទ្ធ** | ឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ០៧/០៨/២០២៦ |
| ២ | លោក **សោម វណ្ណៈ** | ឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ១៤/០៨/២០២៦ |
| **២៩-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** | | | |
| ១ | ឯកឧត្តម **ណុប វណ្ណថារ៉ូ** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ១ | ០២/១២/២០២៦ |
| ២ | លោក **តាន់ ប៊ុនណា** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ០៦/០៨/២០២៦ |

**មាត្រា៣** : សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី *០៤* ខែ *មិថុនា* ឆ្នាំ២០២៦

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាដ៏ត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

*នសរ. ០៦២៦. ៦០៦*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់សុី**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៧៧ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការទទួលស្គាល់វិទ្យាស្ថាន ថាក់ គ្លូបិល

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៧១ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា១០ថ្មី មាត្រា១៤ថ្មី មាត្រា១៥ថ្មី និងមាត្រា១៦ថ្មី នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧



ល

ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៥ មាត្រា១៣ថ្មី មាត្រា៣០ថ្មី និងមាត្រា១១ថ្មីស្ទួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/២៤៣ ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០០៩ និងមាត្រា៦១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

- បានឃើញអនុក្រឹត្យលេខ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## **សម្រេច**

**មាត្រា១ .-**

ត្រូវបានទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាឯកជនដែលមានឈ្មោះថា **វិទ្យាស្ថាន ថាក់ គ្លូបិល** ដែលសរសេរជាអក្សរកាត់ថា **វ.ថ.គ.** និងជាភាសាអង់គ្លេសថា **Tux Global Institute** សរសេរជាអក្សរកាត់ថា **TGI**។

**មាត្រា២ .-**

**វ.ថ.គ.** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន មានអាសយដ្ឋានស្ថិតនៅអគារលេខ៨២២ ផ្លូវSOS ភូមិភ្នំពេញថ្មី សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ និងស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៣ .-**

**វ.ថ.គ.** ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រនិងបរិញ្ញាបត្ររង។

**វ.ថ.គ.** មានដេប៉ាតឺម៉ង់វិទ្យាសាស្ត្រកុំព្យូទ័រ បណ្តុះបណ្តាលលើមុខជំនាញចំនួន៦ ដូចខាងក្រោម៖

១- មុខជំនាញវិស្វកម្មកម្មវិធីកុំព្យូទ័រ បណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រនិងបរិញ្ញាបត្ររង។
២- មុខជំនាញវិស្វកម្មសន្តិសុខតាមអ៊ីនធឺណិតនិងបណ្តាញ បណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រនិងបរិញ្ញាបត្ររង។
៣- មុខជំនាញការរចនាច្នៃប្រឌិតនិងទីផ្សារឌីជីថល បណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រនិងបរិញ្ញាបត្ររង។
៤- មុខជំនាញវិទ្យាសាស្ត្រទិន្នន័យនិងវិភាគ បណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រនិងបរិញ្ញាបត្ររង។
៥- មុខជំនាញការអភិវឌ្ឍកម្មវិធីនិងគេហទំព័រ បណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង។
៦- មុខជំនាញការរចនា UX-UI បណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង។

**មាត្រា៤ .-**

ក្នុងករណីចាំបាច់ដែល **វ.ថ.គ.** ផ្លាស់ប្តូរទីតាំងថ្មី បង្កើតសាខាថ្មី ដេប៉ាតឺម៉ង់ថ្មី មុខជំនាញថ្មី កម្រិតបណ្តុះបណ្តាលថ្មី ឬរៀបចំរចនាសម្ព័ន្ធដេប៉ាតឺម៉ង់ថ្មី ត្រូវស្នើសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៥ .-**

**ខ.ថ.គ.** មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីត្រួតពិនិត្យនិងសម្រេចលើគោលនយោបាយ ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍស្រាវជ្រាវវិទ្យាស្ថាន កម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធសំខាន់ៗផ្សេងៗទៀត។ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែងនៃ **ខ.ថ.គ.** ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៦ .-**

នាយក **ខ.ថ.គ.** មានភារកិច្ច ដូចខាងក្រោម៖

- ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការគ្រប់គ្រង **ខ.ថ.គ.** និងធានាឱ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម
- ទទួលខុសត្រូវក្នុងការជ្រើសរើសនិស្សិត ការទទួលនិស្សិតឱ្យចូលរៀន និងការបញ្ចប់ការសិក្សា ស្របតាមកម្មវិធីសិក្សារបស់ **ខ.ថ.គ.** ព្រមទាំងបទដ្ឋាននិងគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា
- រៀបចំកម្មវិធីសិក្សាលម្អិតឱ្យស្របតាមលក្ខខណ្ឌ និងបទប្បញ្ញត្តិនៃក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- គោរពនិងអនុវត្តតាមបទដ្ឋាននិងគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់លើសកម្មភាពនៃការធានាគុណភាពអប់រំឧត្តមសិក្សា
- រៀបចំរបាយការណ៍ប្រចាំឆ្នាំអំពីការងារបណ្តុះបណ្តាលជូនក្រសួងអប់រំ យុវជន និងកីឡា នៅក្រោយដំណាច់ឆមាសទី២។

**មាត្រា៧ .-**

និស្សិតដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ ត្រូវទទួលសញ្ញាបត្រតាមកម្រិតនិងមុខជំនាញដែលបានសិក្សា។ សញ្ញាបត្រនេះត្រូវផ្តល់ឱ្យដោយ **ខ.ថ.គ.** ផ្អែកលើបញ្ជីឈ្មោះនិស្សិតបញ្ចប់ការសិក្សាជាប់ជាស្ថាពរ ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងនាយកនៃវិទ្យាស្ថាន ថាក់ គ្លូបិល ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៣រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែឧសភា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានីភ្នំពេញ
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៧៤៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរទ្រព្យសម្បត្តិរដ្ឋ និងការកែសម្រួលទំហំដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៧ ស្តីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១ :-**

ត្រូវបានផ្ទេរដី និងអគារចំនួន ២៩ កន្លែង (ដូចមានក្នុងឧបសម្ព័ន្ធទី១) ជូនរដ្ឋបាលស្រុកពាក់ព័ន្ធ និងជម្រះទីតាំងដី និងអគារទាំងនេះ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ និងប្រៃសណីយ៍កម្ពុជា។

ត្រូវបានបំបែកបណ្ណកម្មសិទ្ធិនូវទីតាំងដីចំនួន ២ កន្លែង (ដូចមានក្នុងឧបសម្ព័ន្ធទី២) ជូនប្រៃសណីយ៍កម្ពុជា និងរដ្ឋបាលស្រុក ដូចខាងក្រោម៖

- ទីតាំងដីស្ថិតនៅភូមិកំពង់ត្របែក ឃុំកំពង់ត្របែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ផ្តល់ជូនប្រៃសណីយ៍កម្ពុជា នូវដីទំហំ ១ ១៨៨ ម៉ែត្រការ៉េ ដូចក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។ ចំណែកដីទំហំ ១២៥ ម៉ែត្រការ៉េ ត្រូវផ្តល់ជូនរដ្ឋបាលស្រុកកំពង់ត្របែក
- ទីតាំងដីស្ថិតនៅភូមិជាំក្សាន្ត ឃុំជាំក្សាន្ត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ផ្តល់ជូនប្រៃសណីយ៍កម្ពុជា ទំហំ ៩២០ ម៉ែត្រការ៉េ ដូចក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។ ចំណែកដីទំហំ ៥០៤ ម៉ែត្រការ៉េ ត្រូវផ្តល់ជូនរដ្ឋបាលស្រុកជាំក្សាន្ត។

ត្រូវបានផ្ទេរដី និងជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ នូវទីតាំងដីចំនួន ៤២ កន្លែង (ដូចមានក្នុងឧបសម្ព័ន្ធទី៣) ដូចខាងក្រោម៖

- ប្រគល់ទីតាំងដីចំនួន ៣៩ កន្លែង ជូនប្រៃសណីយ៍កម្ពុជា ក្នុងនោះ អនុញ្ញាតឱ្យប្រៃសណីយ៍កម្ពុជា ចុះបញ្ជីកែសម្រួលក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ នូវទំហំដីដែលមានបណ្ណកម្មសិទ្ធិរួចចំនួន ២៥ កន្លែង និងចុះបញ្ជីកែសម្រួលក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ នូវទំហំដីចំនួន ៧ កន្លែង ផ្សេងទៀត ពេលទទួលបានបណ្ណកម្មសិទ្ធិជាក់ស្តែង ព្រមទាំងអនុញ្ញាតឱ្យចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ នូវទីតាំងដីចំនួន ២ កន្លែង ដែលពុំមានក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។ អនុញ្ញាតឱ្យមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ជម្រះនូវទីតាំង ដីចំនួន ៣៩ កន្លែង ខាងលើ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- បំបែកបណ្ណកម្មសិទ្ធិ នូវទីតាំងដី ១ កន្លែង ស្ថិតនៅភូមិបឹងវែង ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ក្នុងនោះ ផ្តល់ជូនប្រៃសណីយ៍កម្ពុជា កាន់កាប់ទំហំ ៣៦៧ ម៉ែត្រការ៉េ និងទូរគមនាគមន៍កម្ពុជា កាន់កាប់ទំហំ ៦៦២ ម៉ែត្រការ៉េ ព្រមទាំងអនុញ្ញាតឱ្យចុះបញ្ជីកែសម្រួលក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ តាមទំហំដែលបានផ្តល់ជូនជាក់ស្តែង។ អនុញ្ញាតឱ្យមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តព្រះសីហនុ ជម្រះនូវទីតាំងខាងលើ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- រក្សាទុកជាកម្មសិទ្ធិរបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តស្វាយរៀង នូវដីចំនួន ២ កន្លែង និងអនុញ្ញាតឱ្យទូរគមនាគមន៍កម្ពុជាជម្រះ នូវទីតាំងដី ១ កន្លែង ស្ថិតនៅភូមិបាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

**មាត្រា២ :-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។



ល

**មាត្រា៣ :-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៥រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែឧសភា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
ក្រុមការងារត្រួតពិនិត្យដីធ្លី និងអគារនៅតាមក្រុង ស្រុក ទូទាំងប្រទេស
ដើម្បីកាត់ឱ្យប.ក.និងផ្ទេរជូនរដ្ឋបាលក្រុង ស្រុក គ្រប់គ្រង

ឧបសម្ព័ន្ធទី១
ទីតាំងដីធ្លី និងអគារនៅតាមស្រុកដែលត្រូវស្នើសុំផ្តល់ឱ្យរដ្ឋបាលស្រុក
និងជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរ ប.ទ. ខេត្តសាមី និងប្រៃសណីយ៍កម្ពុជា

ឯកតាគិតជាម៉ែត្រការ៉េ

| ល.រ | អាសយដ្ឋាន | ទំហំតាមបញ្ជីសារពើភណ្ឌរបស់មន្ទីរ ប.ទ. | | ទំហំតាមបញ្ជីសារពើភណ្ឌ ប.ក. (ឆ្នាំ២០១០) | | បណ្ណសម្គាល់កម្មសិទ្ធិ | | ស្ថានភាពបច្ចុប្បន្ន | សម្គាល់ |
|---|---|---|---|---|---|---|---|---|---|
| | | ដី | អគារ | ដី | អគារ | មាន | គ្មាន | | |
| ១ | ខេត្តកណ្តាល | | | | | | | | |
២- លោក Azmi Bin Abdul Rahim

៣- លោក Hafiz Othman

៤- លោក Adib Hakim Abdul Rahim
៥- លោក ម៉ាត់ ហូសេន
៦- លោក អេល អាត្រី។

ខ-មេដាយ **សំរឹទ្ធស្ថាបនាជាតិ**

១- លោក ស្មាន កំរិតទីន
២- លោក ឯល ដះរី
៣- លោក មោ វណ្ណី
៤- លោក ឯល ព្រហ៊ីម
៥- លោក ម៉ូត នូរ៉ាវី
៦- លោក កើ ហូ
៧- លោក ទាំ ម៉ាត់។

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៣រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែឧសភា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤០៨ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្ដីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៩៧ ស្ដីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា១ ._**

ត្រូវបានដាក់លោក **នន់ ទ៉ាន់នី** អត្តលេខ ១៦៨០៨០០០៨៧ ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ១ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យចូលនិវត្តន៍មុនអាយុកំណត់តាមការស្នើសុំរបស់សាមីខ្លួន ចាប់ពីថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៦។

**មាត្រា២ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៣រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤០៥ អនក្រ.តត

**អនុក្រឹត្យ**

**ស្ដីពី**

**ការតែងតាំងជំនួយការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៣៧ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ ស្ដីពីគោលការណ៍សម្រាប់ការតែងតាំងទីប្រឹក្សា និងជំនួយការនៅក្នុងអង្គការនីតិប្រតិបត្តិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីការគ្រប់គ្រង និងបើកប្រាក់បំណាច់មុខងារជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីមានឋានៈស្មើ
- បានឃើញអនុក្រឹត្យលេខ២៦៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**មាត្រា១.** _

ត្រូវបានតែងតាំង និងផ្តល់ឋានៈលោក **ហេង សុវណ្ណារិទ្ធ** ជាជំនួយការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានឋានៈស្មើប្រធាននាយកដ្ឋាន។

**មាត្រា២.** _

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៣ រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

កន្លែងទទួល៖
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥៥ សសរ...

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារចំពោះកិច្ចទទួលបន្ទុកពិនិត្យ និងវាយតម្លៃលើលក្ខណៈវិនិច្ឆ័យ សម្រាប់ការជ្រើសរើសវិនិយោគិនក្នុងវិស័យឧស្សាហកម្មកែច្នៃស្វាយចន្ទី នៅក្នុង និងក្រៅតំបន់សេដ្ឋកិច្ចពិសេស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២២៣/២៥៦៤ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៤២ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា គណៈកម្មាធិការវិនិយោគកម្ពុជា និងនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- បានឃើញអនុក្រឹត្យលេខ១៣៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការកែសម្រួលលើមាត្រា៤ ចំណុច ៤.១ និងចំណុច ៤.៣ នៃអនុក្រឹត្យលេខ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**ប្រការ១ .-**

ត្រូវបានបង្កើត "ក្រុមការងារចំពោះកិច្ចទទួលបន្ទុកពិនិត្យ និងវាយតម្លៃលើលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសវិនិយោគិន ក្នុងវិស័យឧស្សាហកម្មកែច្នៃស្វាយចន្ទី នៅក្នុង និងក្រៅតំបន់សេដ្ឋកិច្ចពិសេស" សរសេរជាអក្សរកាត់ថា "**ក.ទ.ក.ស.**" ក្រោមឆ័ត្រក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក.) ដែលមានសមាសភាព ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ជា វុទ្ធី** | អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា (គ.វ.ក.) នៃ ក.អ.ក. | ប្រធាន |
| ២- | ឯកឧត្តមបណ្ឌិតសភាចារ្យ **ផាន់ ផល្លា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- | ឯកឧត្តមបណ្ឌិត **ភេខ ច័ន្ទតារារ័ត្ន** | ទីប្រឹក្សាផ្ទាល់សម្តេចធិបតីនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៤- | ឯកឧត្តម **លឹម សុជាតិ** | ទីប្រឹក្សាផ្ទាល់សម្តេចធិបតីនាយករដ្ឋមន្ត្រី | សមាជិក |
| ៥- | ឯកឧត្តម **សុខ ពិសិដ្ឋ** | ទីប្រឹក្សាផ្ទាល់សម្តេចធិបតីនាយករដ្ឋមន្ត្រី | សមាជិក |
| ៦- | ឯកឧត្តម **នុត អ៊ុនវ័ណារ៉ា** | អគ្គលេខាធិការរង គ.វ.ក. នៃ ក.អ.ក. | សមាជិក |
| ៧- | ឯកឧត្តម **ឃុន ហោខ** | អគ្គលេខាធិការរង គ.វ.ក. នៃ ក.អ.ក. | សមាជិក |
| ៨- | ឯកឧត្តម **លឹម វិសាល** | អគ្គលេខាធិការរង គ.វ.ក. នៃ ក.អ.ក. | សមាជិក |
| ៩- | ឯកឧត្តមបណ្ឌិត **សរ សិនិរ៉ា** | អគ្គលេខាធិការរង គ.វ.ក. នៃ ក.អ.ក. | សមាជិក |
| ១០- | លោក **ហៀន សុប៉ូលីន** | ប្រធានស្តីទីនាយកដ្ឋានប្រតិបត្តិការ និងគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសនៃក.អ.ក/គ.វ.ក. | សមាជិក |
| ១១- | លោក **សេខ ស៊ុនលី** | ប្រធានស្តីទីនាយកដ្ឋានវិភាគយុទ្ធសាស្ត្រនៃការវិនិយោគជននៃ ក.អ.ក./គ.វ.ក. | សមាជិក។ |

**ប្រការ២ .-**

**ក.ទ.ក.ស.** មានភារកិច្ច ដូចខាងក្រោម៖

– ពិនិត្យ វិភាគ និងវាយតម្លៃ លើសំណើសុំវិនិយោគលើគម្រោងវិនិយោគក្នុងវិស័យឧស្សាហកម្មកែច្នៃស្វាយចន្ទី ដែលមានទីតាំងវិនិយោគនៅក្នុង ឬក្រៅតំបន់សេដ្ឋកិច្ចពិសេស ផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានទទួលការ

ឯកភាពពីប្រមុខរាជរដ្ឋាភិបាល ព្រមទាំងលើកយោបល់ជូននាយករដ្ឋមន្ត្រី និងជាប្រធាន ក.អ.ក. ដើម្បីពិនិត្យ និងសម្រេចលើការផ្តល់ការលើកទឹកចិត្ត និងការអនុគ្រោះនានាពីរាជរដ្ឋាភិបាល

- ពិនិត្យ តាមដាន និងរាយការណ៍ជាប្រចាំអំពីវឌ្ឍនភាពនៃការអនុវត្តគម្រោង ព្រមទាំងសំណូមពរនានាទៅនាយករដ្ឋមន្ត្រី ដោយផ្ទាល់
- អនុវត្តភារកិច្ចដទៃទៀត តាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

**ប្រការ៣ .-**

ប្រធាន **គ.វ.គ.ស.** ទទួលបន្ទុករួមក្នុងការដឹកនាំក្រុមការងារ និងដឹកនាំកិច្ចប្រជុំ។ ក្នុងករណីចាំបាច់ឬប្រធានអវត្តមាន អាចចាត់តាំងអនុប្រធាន ឬសមាជិកមួយរូបដឹកនាំការងារ និងកិច្ចប្រជុំជំនួស ។ អនុប្រធាន និងសមាជិកត្រូវចូលរួមកិច្ចប្រជុំតាមការកោះអញ្ជើញរបស់ប្រធានអង្គប្រជុំ។

**គ.វ.គ.ស.** មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលទទួលបានប្រតិភូកម្ម ឬមានសិទ្ធិសម្រេចក្នុងនាមប្រធានស្ថាប័ន ដើម្បីចូលរួមក្នុងការពិនិត្យ វិភាគ និងវាយតម្លៃលើគម្រោងវិនិយោគ។

**គ.វ.គ.ស.** មានលេខាធិការដ្ឋានមួយជាសេនាធិការ ដើម្បីទទួលបន្ទុកសម្របសម្រួលការងាររដ្ឋបាល និងបច្ចេកទេសគាំទ្រដល់ការអនុវត្តការងាររបស់ខ្លួន។ សមាសភាព និងរបៀបរបបការងាររបស់លេខាធិការដ្ឋាននៃ **គ.វ.គ.ស.** ត្រូវអនុលោមតាមការកំណត់របស់ប្រធាន **គ.វ.គ.ស.**។

**ប្រការ៤ .-**

**គ.វ.គ.ស.** មានធនធានហិរញ្ញវត្ថុក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

**គ.វ.គ.ស.** មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្រាប់បំពេញភារកិច្ចរបស់ខ្លួន។

**ប្រការ៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អនុប្រធានទី២ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អនុប្រធានទី៣ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៥ រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០.

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែឧសភា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

៧/៣

## រំហូរនៃការចុះបញ្ជីគម្រោងវិនិយោគកែច្នៃស្វាយចន្ទី




*ក.វ.ក.ស. ៖ ក្រុមការងារចំពោះកិច្ចទទួលបន្ទុកពិនិត្យ និងវាយតម្លៃលើលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសវិនិយោគិនក្នុងវិស័យឧស្សាហកម្មកែច្នៃស្វាយចន្ទីនៅក្នុង និងក្រៅតំបន់សេដ្ឋកិច្ចពិសេស

**គ.វ.ក. នៃ ក.អ.ក. ៖ គណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា




*The task force: task force on reviewing and evaluating criteria for selecting cashew processing investors inside and outside special economic zones

* *The CIB/CDC: the Cambodian Investment Board of the Council for the Development of Cambodia

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.......សហវ.........

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការបង្កើតរង្វាន់ចំណូល
# នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម /០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការធ្វើវិសោធនកម្មមាត្រា ៩ និងមាត្រា ១០ នៃច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២៥/០៤០ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្ដីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ស្ដីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលឱ្យស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្ដីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣ នៃអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៤៥ អនក្រ.បក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ ស្ដីពីគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ២៥៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៤ ស្ដីពីការបែងចែកឥណទានចំណូលថវិកាជាតិតាមជំពូកនៃច្បាប់ស្ដីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦
- បានឃើញបញ្ជាលេខ ០៤ បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្ដីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញប្រកាសលេខ៥៤៤ សហវ.ប្រក ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ ស្ដីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិការបស់អង្គភាពថវិកា
- បានឃើញប្រកាសលេខ ១១៥៨ សហវ.ប្រក.អរតន ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ស្ដីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ៩៧៤ សហវ.ប្រក.អរតន ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៥ ស្ដីពីនីតិវិធីនៃការគ្រប់គ្រងរដ្ឋទេយ្យចំណូលសម្រាប់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ១០៦៥ សហវ.ប្រក.អថ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៥ ស្ដីពីការប្រគល់កាតព្វកិច្ចប្រមូលចំណូលថវិកាថ្នាក់ជាតិ សម្រាប់ឆ្នាំ២០២៦
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**ប្រការ១._**

ត្រូវបានបង្កើតរជ្ជទេយ្យចំណូលនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីប្រមូលចំណូលមិនមែនសារពើពន្ធផ្សេងៗអនុលោមតាមបទប្បញ្ញត្តិជាធរមាន។ បញ្ជីរាយប្រភេទចំណូលដែលត្រូវបង្កើតរជ្ជទេយ្យចំណូលសម្រាប់ឆ្នាំ២០២៦ មានដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. | អនុគណនីលេខ៧៣០៤៨ | ផលពីសេវាកម្មផ្សេងៗ | ចំនួនទឹកប្រាក់ | ១ ៦៥០ 000 000៛00 |
| ២. | អនុគណនីលេខ៧៣០៨២ | ផលពីការផ្តល់ទិដ្ឋាការ | ចំនួនទឹកប្រាក់ | ១២០ 000 000 000៛00 |
| | | | **សរុបទឹកប្រាក់៖** | **១២១ ៦៥០ 000 000៛00** |

**ប្រការ២._**

ចំនួនទឹកប្រាក់អតិបរិមា ដែលអនុញ្ញាតទុកនៅក្នុងបេឡាមានកំណត់ត្រឹមចំនួន ២ ០០០ ០០០៛០០ (ពីរលានរៀលគត់) ។

**ប្រការ៣._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៤._**

អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ប្រធានអង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ ដូចមានចែងក្នុងប្រការ១ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៣ រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

**ប្រាក់ សុខុន**

<u>កន្លែងទទួល៖</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
ចូល លេខ 2614
ថ្ងៃទី 26 ខែ 05 ឆ្នាំ 26
ម៉ោង 10h09

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៣៦៤ សហវ.ប្រក

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការផ្តល់សេវាសាធារណៈរហ័សលើវិស័យសុរិយោដី និងភូមិសាស្ត្រ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia



ទូរស័ព្ទ: (+៨៥៥) ២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិ
- បានឃើញអនុក្រឹត្យលេខ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា១៦ និងមាត្រា១៧ នៃអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងនិងការប្រើប្រាស់អគារសហកម្មសិទ្ធិ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងលើការវាស់វែងនិងការផលិតផែនទី និងលើអាជីវកម្មវាស់វែងនិងការផលិតផែនទី
- បានឃើញអនុក្រឹត្យលេខ១២១ អនក្រ.បក ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៩ និងមាត្រា១៣ នៃអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ
- បានឃើញអនុក្រឹត្យលេខ១២២ អនក្រ.បក ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៦ មាត្រា៧ និងមាត្រា១១ នៃអនុក្រឹត្យលេខ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីគោលការណ៍ និងនីតិវិធីបន្ថែមសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធក្នុងក្របខ័ណ្ឌនៃការផ្ទេរមុខងារ និងការបែងចែកចំណូលមិនមែនសារពើពន្ធ ពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤ ស្តីពីនីតិវិធីគ្រប់គ្រង និងអនុវត្តថវិកាសម្រាប់យុទ្ធនាការជំរុញការចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធ
- បានឃើញប្រកាសអន្តរក្រសួងលេខ១៨៦ សហវ.ប្រក.អទច ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៦ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

អនុញ្ញាតឱ្យរដ្ឋបាលកណ្តាលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ផ្តល់សេវាសាធារណៈរហ័សលើវិស័យសុរិយោដី និងភូមិសាស្ត្រ ដើម្បីផ្តល់ជម្រើសបន្ថែមជូនប្រជាពលរដ្ឋ និងធុរជន ស្របតាមការវិវឌ្ឍរីកចម្រើនផ្នែកសេដ្ឋកិច្ច សង្គម និងបច្ចេកវិទ្យា។

ការផ្តល់សេវាសាធារណៈរហ័សលើវិស័យសុរិយោដី និងភូមិសាស្ត្រ ដោយរដ្ឋបាលកណ្តាលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវអនុវត្តតាមកម្រងសេវាសាធារណៈដែលចែងក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងលេខ១៨៦ សហវ.ប្រក.អទច ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៦ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

រដ្ឋបាលរាជធានី ខេត្ត និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវអនុវត្តតួនាទី និងភារកិច្ចអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន និងបន្តផ្តល់សេវាសាធារណៈលើវិស័យសុរិយោដី និងភូមិសាស្ត្រ ដោយអនុវត្តតាមកម្រងសេវាសាធារណៈដែលចែងក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងលេខ១៨៦ សហវ.ប្រក.អទច ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៦ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ២ .-**

ចំណូលប្រមូលបានពីការផ្តល់សេវាសាធារណៈរហ័សលើវិស័យសុរិយោដីនិងភូមិសាស្ត្រ ដែលកំណត់ក្នុងប្រការ១ នៃប្រកាសអន្តរក្រសួងនេះ ត្រូវកត់ត្រាជាចំណូលរបស់រដ្ឋបាលកណ្តាលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលជាចំណូលរបស់រដ្ឋបាលថ្នាក់ជាតិ។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**សាយ សំអាល់**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អង្គភាពប្រឆាំងអំពើពុករលួយ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងផែនការ**
លេខ : ២៩៦ ផក

ទីស្តីការគណៈរដ្ឋមន្ត្រី
ចូល
លេខ 2700
ថ្ងៃទី 29 ខែ 05 ឆ្នាំ 26
ម៉ោង 2H 32

**ប្រកាសអន្តរក្រសួង**
**ស្តីពី**
**ការផ្លាស់ប្តូរទិន្នន័យសុខាភិបាល**

**រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៨ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្ថិតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម
- បានឃើញអនុក្រឹត្យលេខ១៨១ អនក្រ.បក ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ
- បានឃើញអនុក្រឹត្យលេខ១៤៤ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ

- បានឃើញអនុក្រឹត្យលេខ២៣៩ អនក្រ.បក ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង
- បានឃើញអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៥ ស្តីពីការបង្កើតវិទ្យាស្ថានជាតិស្ថិតិ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ
- បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៥ ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីការបង្កើតវិទ្យាស្ថានជាតិស្ថិតិ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ
- បានឃើញអនុក្រឹត្យលេខ៨៥ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃវិទ្យាស្ថានជាតិស្ថិតិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងផែនការ និងក្រសួងសុខាភិបាល

## សម្រេច

**ប្រការ១ .–**

ប្រកាសអន្តរក្រសួងនេះ មានគោលបំណងកំណត់នីតិវិធីអំពីការផ្លាស់ប្តូរទិន្នន័យអត្រានុកូលដ្ឋាន និងទិន្នន័យសូចនាករសុខាភិបាល រវាងក្រសួងសុខាភិបាល និងក្រសួងផែនការ ដើម្បីធានាបាននូវការប្រើប្រាស់ទិន្នន័យ និងការផលិតរបាយការណ៍ប្រកបដោយភាពទៀងទាត់ ទាន់ពេលវេលា និងមានប្រសិទ្ធភាព។

**ប្រការ២ .–**

ប្រកាសអន្តរក្រសួងនេះ មានវិសាលភាពអនុវត្តចំពោះការផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធព័ត៌មានសុខាភិបាលនៃក្រសួងសុខាភិបាល និងប្រព័ន្ធថ្នាលទិន្នន័យសូចនាករអភិវឌ្ឍន៍ជាតិ(ខេមស្តាត) របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។

**ប្រការ៣ .–**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងប្រកាសអន្តរក្រសួងនេះ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ៤ .–**

ក្រសួងសុខាភិបាល មិនត្រូវបញ្ជូនទិន្នន័យដែលអាចកំណត់អត្តសញ្ញាណបុគ្គលបាន មានជាអាទិ៍ ឈ្មោះ លេខអត្តសញ្ញាណបុគ្គល លេខផ្ទះ លេខផ្លូវ លេខទូរសព្ទ និងអ៊ីមែល ទៅវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការឡើយ។

**ប្រការ៥ .–**

ការផ្លាស់ប្តូរទិន្នន័យត្រូវធ្វើឡើងដូចខាងក្រោម៖

- ក្រសួងសុខាភិបាល ត្រូវបញ្ជូនទិន្នន័យបុគ្គលអំពីមរណភាព មូលហេតុមរណភាព និងទារកស្លាប់កើត ទៅវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ រៀងរាល់៣ខែម្តង តាមរយៈសន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ (API) ដែលបានកំណត់ នូវប្រភេទទិន្នន័យដូចមានចែងក្នុងឧបសម្ព័ន្ធទី២ និងឧបសម្ព័ន្ធទី៣ នៃប្រកាសអន្តរក្រសួងនេះ

- ក្រសួងសុខាភិបាល ត្រូវបញ្ជូនទិន្នន័យមូលហេតុមរណភាពតាមរយៈការសាកសួរផ្ទាល់មាត់ ជាប្រចាំឆ្នាំនៅរៀងរាល់ខែមករា តាមវិធីសាស្ត្រ និងទម្រង់ដែលបានកំណត់ នូវប្រភេទទិន្នន័យដូចមានចែងក្នុងឧបសម្ព័ន្ធទី៤ នៃប្រកាសអន្តរក្រសួងនេះ
- ក្រសួងសុខាភិបាល ត្រូវបញ្ជូនទិន្នន័យសូចនាករសុខាភិបាល ជាប្រចាំឆ្នាំនៅរៀងរាល់ខែមេសា តាមវិធីសាស្ត្រ និងទម្រង់ទិន្នន័យរបស់ថ្នាលខេមស្តាត នូវប្រភេទទិន្នន័យដូចមានចែងក្នុងឧបសម្ព័ន្ធទី៥ នៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ៦ .-**

ការកែសម្រួល ឬការផ្លាស់ប្តូរខ្លឹមសារណាមួយនៃប្រកាសអន្តរក្រសួងនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងក្រសួងសុខាភិបាល និងក្រសួងផែនការ តាមការចាំបាច់។

**ប្រការ៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៨ .-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងគ្រប់ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសុខាភិបាល និងក្រសួងផែនការ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១០រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៦

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

សាស្ត្រាចារ្យ **ឈាង រ៉ា**

**រដ្ឋមន្ត្រីក្រសួងផែនការ**

**ប៊ិន ត្រឈៃ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងផែនការ
- ខុទ្ទកាល័យឯកឧត្តមសាស្ត្រាចារ្យរដ្ឋមន្ត្រីក្រសួងសុខាភិបាល
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងលេខ..២៥៦ សអ..ចុះថ្ងៃទី...៣...ខែ...មេសា...ឆ្នាំ..២០២៦
## ស្តីពីការផ្លាស់ប្តូរទិន្នន័យសុខាភិបាល

❖ វាក្យស័ព្ទសំខាន់ៗដែលប្រើក្នុងប្រកាសអន្តរក្រសួងនេះត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- **សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ** (Application Programming Interface - API)៖ សំដៅដល់ច្រកចេញចូលស្តង់ដាដែលអនុញ្ញាតឱ្យទិន្នន័យអាចផ្លាស់ប្តូរពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយ ទៅប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយផ្សេងទៀត។
- **មរណភាព** (Death)៖ សំដៅដល់ការបាត់បង់ជាអចិន្ត្រៃយ៍នូវរាល់ភស្តុតាងនៃជីវិតនៅក្នុងពេលណាមួយក្រោយកំណើតរស់។
- **ទារកស្លាប់កើត** (Fetal Death)៖ សំដៅដល់ការស្លាប់របស់ទារកមុនពេលធ្លាក់ចេញ ឬទាញយកចេញទាំងអស់នូវទារក និងសាខាទារក (មានជាអាទិ៍ សុក ទងសុក ទឹកភ្លោះ និងថង់ទឹកភ្លោះ) ពីផ្ទៃរបស់ម្តាយដោយមិនគិតរយៈពេលនៃការមានគភ៌។ ការស្លាប់នេះត្រូវបានស្តែងចេញឱ្យឃើញថាក្រោយការចាកចេញពីផ្ទៃម្តាយ ទារកនោះពុំមានសញ្ញាបង្ហាញ ថានៅមានជីវិតដូចជាពុំមានដកដង្ហើម ចង្វាក់បេះដូង ជីពចរទងសុក និងចលនាសាច់ដុំជាដើម។
- **មូលដ្ឋានសុខាភិបាល** (Health Facility)៖ សំដៅដល់មូលដ្ឋានសុខាភិបាលសាធារណៈ និងឯកជន។
- **មូលដ្ឋានសុខាភិបាលសាធារណៈ** (Public Health Facility)៖ សំដៅដល់មន្ទីរពេទ្យជាតិ មន្ទីរពេទ្យយោធា មន្ទីរពេទ្យនគរបាលជាតិ និងមន្ទីរពេទ្យបង្អែករាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មណ្ឌលសុខភាព ប៉ុស្តិ៍សុខភាព និងប៉ុស្តិ៍សុខភាពពន្ធនាគារ។
- **មូលដ្ឋានសុខាភិបាលឯកជន** (Private Health Facility)៖ សំដៅដល់មន្ទីរពេទ្យឯកជន មន្ទីរពហុព្យាបាល មន្ទីរសម្រាក ព្យាបាល មន្ទីរសម្ភពរោគស្ត្រី និងគ្លីនិកឯកជន រួមទាំងសេវាព្យាបាលរបស់អង្គការមិនមែនរដ្ឋាភិបាល និងសមាគម។
- **លិខិតវេជ្ជសាស្ត្របញ្ជាក់ពីមូលហេតុមរណភាព** (Medical Certificate of Cause of Death-MCCD)៖ សំដៅដល់ទម្រង់លិខិតបញ្ជាក់វេជ្ជសាស្ត្រដែលត្រូវបានបំពេញដោយគ្រូពេទ្យដើម្បី ធ្វើការកត់ត្រាទិន្នន័យ មូលហេតុមរណភាព និងប្រភេទនៃមរណភាព។
- **មូលហេតុនៃមរណភាព** (Cause of Death)៖ សំដៅដល់ជំងឺ ឬការរងរបួសដែលបានចាប់ផ្តើមជាខ្សែច្រវាក់នៃព្រឹត្តិការណ៍ជំងឺ ឬអំពើហិង្សាដែលបង្កើតឱ្យមានរបួសធ្ងន់ធ្ងរដែលនាំទៅដល់ការស្លាប់។ និយមន័យនេះមានគោលបំណងធានាថារាល់ព័ត៌មានពាក់ព័ន្ធត្រូវបានកត់ត្រា និងធានាថាអ្នកផ្តល់ការបញ្ជាក់មូលហេតុនៃមរណភាព មិនជ្រើសរើសយកតែលក្ខខណ្ឌមួយចំនួនសម្រាប់កត់ត្រាបញ្ចូល និងប្រានចោលលក្ខខណ្ឌដទៃទៀត។
- **មូលហេតុដើមនៃមរណភាព** (Final Underlying Cause of Death-FUCOD)៖ សំដៅដល់រាល់ជំងឺ ឬរបួសដែលបានផ្តួចផ្តើមជាខ្សែច្រវាក់នៃព្រឹត្តិការណ៍ជំងឺដែលឈានទៅដល់ការស្លាប់ ឬកាលៈទេសៈនៃឧបទ្ទវហេតុ ឬអំពើហិង្សាដែលបង្កើតឱ្យមានរបួសធ្ងន់ធ្ងររហូតដល់ស្លាប់។
- **ទិន្នន័យអត្តសញ្ញាណបុគ្គល** (Individual Identification Data)៖ សំដៅដល់ព័ត៌មាននានា ដែលអាចកំណត់អត្តសញ្ញាណបុគ្គលណាម្នាក់បាន។
- **មូលហេតុមរណភាពតាមរយៈការសាកសួរផ្ទាល់មាត់** (Verbal Autopsy-VA)៖ ជាវិធីសាស្ត្រផ្អែកលើសហគមន៍ដែលមានសុពលភាពសម្រាប់ប៉ាន់ស្មានមូលហេតុមរណភាពដោយប្រើព័ត៌មានទទួលបានពីអ្នកមើលថែទាំមរណជនមុនពេលស្លាប់។

## ឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងលេខ..២៥៦...អ.ក..ចុះថ្ងៃទី...១៣...ខែ....មេសា...ឆ្នាំ..២០២៦
## ស្តីពីការផ្លាស់ប្តូរទិន្នន័យសុខាភិបាល

❖ ប្រភេទទិន្នន័យទារកស្លាប់កើត មានដូចខាងក្រោម៖

ក. កាលបរិច្ឆេទសម្រាលទារកស្លាប់កើត

ខ. ទីកន្លែងសម្រាលទារកស្លាប់កើត

គ. ភេទនៃទារកស្លាប់កើត (ប្រសិនបើដឹង)

ឃ. អាយុរបស់ទារកស្លាប់កើត

ង. មូលហេតុដើមនៃការស្លាប់របស់ទារក (ប្រសិនបើដឹង) (ឈ្មោះ និងកូដមរណភាព)

ច. ថ្ងៃខែឆ្នាំកំណើតរបស់ម្តាយ

ឆ. ទីលំនៅជាប្រក្រតីរបស់ម្តាយ

ជ. ចំនួនកំណើតរស់ដែលម្តាយបានសម្រាលក្នុងមួយជីវិត (គិតត្រឹមពេលរាយការណ៍)

ឈ. ចំនួនទារកស្លាប់កើតដែលម្តាយបានសម្រាលក្នុងមួយជីវិត (គិតត្រឹមពេលរាយការណ៍)។

## ឧបសម្ព័ន្ធទី៣ នៃប្រកាសអន្តរក្រសួងលេខ២៥៦ អក ចុះថ្ងៃទី ៣ ខែ មករា ឆ្នាំ ២០២៦
## ស្តីពីការផ្លាស់ប្តូរទិន្នន័យសុខាភិបាល

❖ ប្រភេទទិន្នន័យមរណភាព មានដូចខាងក្រោម៖

ក. កាលបរិច្ឆេទមរណភាពរបស់មរណជន

ខ. ថ្ងៃខែឆ្នាំកំណើតរបស់មរណជន ឬអាយុរបស់មរណជន ប្រសិនបើមិនស្គាល់កាលបរិច្ឆេទនៃមរណភាព

គ. ភេទរបស់មរណជន

ឃ. ទីកន្លែងទទួលមរណភាព

ង. ប្រភេទនៃទីកន្លែងទទួលមរណភាព

ច. ទីលំនៅរបស់មរណជន ឬទីលំនៅរបស់ម្តាយ ក្នុងករណីមរណភាពទារក

ឆ. មូលហេតុដើមនៃមរណភាព (ឈ្មោះ និងកូដមរណភាព)

ជ. ប្រភេទនៃមរណភាព (ប្រក្រតី ឬមិនប្រក្រតី)។

## ឧបសម្ព័ន្ធទី៤ នៃប្រកាសអន្តរក្រសួងលេខ២៥៦ ឧស.ចុះថ្ងៃទី.៣....ខែ.មករា...ឆ្នាំ.២០២៦
## ស្តីពីការផ្លាស់ប្តូរទិន្នន័យសុខាភិបាល

❖ ប្រភេទទិន្នន័យមូលហេតុមរណភាពតាមរយៈការសាកសួរផ្ទាល់មាត់ (Verbal Autopsy-VA) មានដូចខាងក្រោម៖

ក. ថ្ងៃខែឆ្នាំទទួលមរណភាពកាលបរិច្ឆេទមរណភាពរបស់មរណជន

ខ. ថ្ងៃខែឆ្នាំកំណើតរបស់មរណជន ឬអាយុនៃមរណជន ប្រសិនបើមិនស្គាល់កាលបរិច្ឆេទនៃមរណភាព

គ. ភេទរបស់មរណជន

ឃ. ទីកន្លែងទទួលមរណភាព

ង. ទីលំនៅរបស់មរណជន ឬទីលំនៅរបស់ម្តាយ ក្នុងករណីមរណជនជាទារក

ច. ប្រហែលជាមូលហេតុដើមនៃមរណភាព (ឈ្មោះ)

ឆ. ប្រភេទនៃមរណភាព (ប្រក្រតី ឬមិនប្រក្រតី)។

**ឧបសម្ព័ន្ធទី៥ នៃប្រកាសអន្តរក្រសួងលេខ...........ចុះថ្ងៃទី.......ខែ........ឆ្នាំ........**
**ស្តីពីការផ្លាស់ប្តូរទិន្នន័យសុខាភិបាល**

❖ ប្រភេទទិន្នន័យសូចនាករសុខាភិបាលសំខាន់ៗ រួមមាន៖

១. អត្រាមរណភាពមាតា

២. អត្រាស្លាប់ទារក

៣. អត្រាស្លាប់កុមារអាយុក្រោម៥ឆ្នាំ

៤. អត្រាស្គមស្គាំងលើកុមារអាយុ៥ឆ្នាំ

៥. សមាមាត្រនៃស្ត្រីក្នុងវ័យបន្តពូជ(១៥-៤៩ឆ្នាំ) ដែលត្រូវការសេវាផែនការគ្រួសារបានពេញចិត្តនឹងមធ្យោបាយពន្យាកំណើតទំនើប

៦. ភាគរយនៃស្ត្រីមានគភ៌បានទទួលការថែទាំមុនសម្រាល ៤លើក ដោយបុគ្គលិកសុខាភិបាល

៧. ភាគរយនៃស្ត្រីសម្រាលទទួលការពិនិត្យថែទាំក្រោយសម្រាលលើកទី១ (មុន៤៨ម៉ោង ក្រោយសម្រាល) ដោយបុគ្គលិកសុខាភិបាល

៨. សមាមាត្រនៃការសម្រាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ

៩. ភាគរយនៃទារកបានទទួលការបំបៅដោយទឹកដោះម្តាយក្នុងអំឡុងមួយម៉ោងដំបូងនៃកំណើត

១០. អត្រាគ្របដណ្តប់នៃវ៉ាក់សាំងបង្ការកញ្ជ្រឹល-ស្អូច ដូសទី១

១១. ករណីថ្មីពិនិត្យពិគ្រោះជំងឺក្រៅលើកុមារអាយុក្រោម៥ឆ្នាំម្នាក់ ក្នុងមួយឆ្នាំ

១២. អត្រាគ្របដណ្តប់នៃវ៉ាក់សាំង៣ដូសបង្ការជំងឺខាន់ស្លាក់ ស្វិតដៃជើង តេតាណូស រលាកសួត

១៣. ករណីឆ្លងថ្មី(អាំងស៊ីដង់) នៃមេរោគអេដស៍ក្នុងប្រជាជនដែលគ្មានផ្ទុកមេរោគអេដស៍ ១ ០០០នាក់

១៤. ភាគរយនៃអ្នករស់នៅជាមួយមេរោគអេដស៍ (មនុស្សពេញវ័យនិងកុមារ) ដែលកំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ បានធ្វើតេស្ត viral load ហើយមានលទ្ធផល viral load suppressed ក្នុងរយៈពេល១២ខែកន្លងមក

១៥. ករណីថ្មីនៃជំងឺរបេងគ្រប់សណ្ឋាន

១៦. អត្រាស្លាប់ដោយជំងឺរបេង

១៧. អត្រាព្យាបាលជោគជ័យនៃជំងឺរបេង

១៨. អត្រាស្លាប់នៃជំងឺគ្រុនចាញ់ រាយការណ៍ដោយមូលដ្ឋានសុខាភិបាលសាធារណៈ

១៩. ករណីថ្មីនៃជំងឺគ្រុនចាញ់

២០. អត្រាស្លាប់បណ្តាលមកពីជំងឺមិនឆ្លងណាមួយក្នុងចំណោមជំងឺបេះដូង-សរសៃឈាម ទឹកនោមផ្អែម មហារីក ឬផ្លូវដង្ហើមរ៉ាំរ៉ៃ

២១. ប្រេវ៉ាឡង់នៃការប្រើប្រាស់ថ្នាំជក់ក្នុងចំណោមប្រជាជនអាយុលើសពី១៥ឆ្នាំ/អាយុ១៣-១៥ឆ្នាំ

២២. ប្រេវ៉ាឡង់នៃការប្រើប្រាស់គ្រឿងស្រវឹងក្នុងចំណោមមនុស្សពេញវ័យចាប់ពីអាយុ១៨ឆ្នាំ

២៣. ភាគរយនៃប្រជាជនពេញវ័យមានជំងឺធ្លាក់ទឹកចិត្តបានទទួលការពិនិត្យព្យាបាល

២៤. អត្រាវះកាត់ជំងឺភ្នែកឡើងបាយក្នុងចំណោមប្រជាជន១លាននាក់

២៥. សន្ទស្សន៍គ្របដណ្តប់សេវាសុខភាពនៃការគ្របដណ្តប់សុខភាពជាសកល

២៦. ភាគរយនៃពលរដ្ឋដែលគ្របដណ្តប់ដោយប្រព័ន្ធគាំពារសុខភាពសង្គម
២៧. ភាគរយនៃមណ្ឌលសុខភាពទទួលបានពិន្ទុគុណភាពលើសពី៦០%
២៨. ភាគរយមន្ទីរពេទ្យបង្អែកកម្រិត១/២/៣ ទទួលបានពិន្ទុគុណភាពលើសពី៦០%
២៩. អត្រានៃការពេញចិត្តរបស់អ្នកជំងឺ/អតិថិជន ចំពោះសេវាថែទាំសុខភាពដែលផ្តល់ដោយមណ្ឌលសុខភាព/មន្ទីរពេទ្យបង្អែក
៣០. ពិន្ទុសមត្ថភាពស្នូលនៃនិយ័តកម្មសុខភាពអន្តរជាតិ
៣១. អនុបាតវេជ្ជបណ្ឌិត គិលានុបដ្ឋាក ឆ្មប-ប្រជាជន
៣២. ចំនួនលើកនៃការពិគ្រោះជំងឺក្រៅករណីថ្មីរបស់ប្រជាជនមួយនាក់ក្នុងមួយឆ្នាំ
៣៣. អត្រាស្លាប់នៅមន្ទីរពេទ្យ
៣៤. ភាគរយនៃការផ្តល់ឈាមដោយអ្នកស្ម័គ្រចិត្ត
៣៥. សន្ទស្សន៍គុណភាពទិន្នន័យសុខាភិបាល
៣៦. ភាគរយនៃមណ្ឌលសុខភាពដែលមានគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាពដំណើរការពេញលេញ។

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងបណ្ណសារជាតិ
ទីស្ដីការគណៈរដ្ឋមន្ត្រី